ឆ្វាយហួសពីជើងមេឃ

៥ ឆ្នាំ ជាមួយពួកខ្មែរក្រហម

បកប្រែពីភាសា បារាំង

ដោយ

ខ្ឿន ភាញ្ញារីឆ្ន

ការផ្សាយលើកទី ២

អារម្ភកថារបស់អ្នកបកប្រែ

ក្រោយពីការដកស្រង់ភាគខ្លះ នៃស្យៅវភៅរ៉ាយរ៉ាប់ពីជីវិតរបស់នារី បារាំងឈ្មោះ **ឡូរ៉ង់ពិច** មកចុះនៅកាសែត **កម្ពុជា** មក មានមិត្តអ្នកអាននៅគ្រប់មជ្ឈដ្ឋានបានផ្ញើលិខិតជាច្រើនទាមទារអោយបោះផ្សាយស្យៅវភៅនេះទាំងស្រុង ។ ខ្ញុំបាទក៏បានឆ្លៀតពេលបន្តិចបន្តួចក្រៅម៉ោងធ្វើការដើម្បីព្យាយាមបកប្រែស្យៅវភៅនេះឡើង ។ ដោយហេតុនេះហើយទើបស្យៅវភៅ <<**ឆ្ងាយហួសពីជើងមេឃ**>> ជាភាសាខ្មែរនេះចេញយឹតយូរបន្តិច ។ ខ្ញុំបាទសូមមិត្តអ្នកអានទាំងអស់អធ្យាស្រ័យដោយអនុគ្រោះ ។

ស្យៅវភៅនេះរំលឹកយើងពីសម័យដ៏ខ្មៅងងឹតមួយនៃមាតុភូមិ និង ប្រជាជនយើង ។ នោះគឺជាដំណើររឿងនៃនារីបរទេសម្នាក់ដែលបានស្រមើស្រមៃបំពេញឧត្តមគតិបដិវត្តន៍មួយ ហើយបន្តិចម្តង១ ការស្រមើស្រមៃនោះក៏បានរលាយបាត់ទៅ១ នៅចំពោះមុខតថភាពដ៏គួរអោយខ្លាចរន្ធត់មួយ ។ មកដល់បច្ចុប្បន្ននេះ ស្យៅវភៅរបស់**ឡូរ៉ង់ពិច** ស្ថិតនៅជាស្យៅវភៅតែមួយគត់ ដែលបាននិយាយពីស្ថានភាពរបស់កម្ពុជាប្រជាធិបតេយ្យពីផ្ទៃក្នុងតែម្តង ។ ប៉ុន្តែនេះគឺជាស្យៅវភៅដែលនិយាយពីកម្ពុជាតាមក្រសែភ្នែករបស់អ្នកបរទេសម្នាក់ ដោយហេតុនេះជាបរានុម័តទស្សនៈរបស់ស្មេរក៏អាចមិនបានគ្រប់ជ្រុងជ្រោយ រឺ ក៏មិនអាចដូចទស្សនៈរបស់យើងទាំងស្រុងឡើយ ។

ខ្ញុំបាទបកប្រែស្យៅវភៅនេះ ដើម្បីឧទ្ទិសដល់ញាតិ មិត្ត និង ជនរួមជាតិ ទាំងអស់ដែលបានស្លាប់យ៉ាងវេទនានៅពាសពេញព្រៃ ដី ភ្នំ ត្រពាំង បឹងបួរ អណ្តូង ផ្ទុក នៃមាតុភូមិអង្គរ និងដើម្បីកុំអោយយើង << ភ្លេច >> មេរៀននេះ និងពីសេសដើម្បីយូរ ១ ម្តងយើងសាកពិចារណាពីអ្វីដែល<< គួរ >> និងអ្វីដែល<< មិនគួរ>> ... ។

ព្រឹកនោះ អាកាសយានដ្ឋានប៉ែកាំងមានធាតុអាកាសត្រជាក់ស្រឹប ។ រដូវទឹកកកទើបមកដល់ ហើយជនជាតិចិនក៏បានចាប់ផ្តើមពាក់អាវញាត់គរបស់ខ្លួនឡើងវិញដែរ ។

ថ្ងៃនោះគឺជាថ្ងៃទី ១០ តុលា ១៩៧៥ ។ ខ្ញុំរៀបចេញដំណើរហើយ ។ គឺជាការលំបាកនឹងឃ្លាតចាកពីទីក្រុងដែលខ្ញុំធ្លាប់បានរស់នៅជាង ៦ ឆ្នាំ មក ហើយនេះណាស់ ។ ជាទីក្រុងប៉ែកាំងដ៏ល្អូកល្អឺន និងជាប៉ែកាំងដ៏តឹងតែង អាស្រ័យដោយរដូវទឹកកកវឹងថ្គាម រដូវក្តៅហែង រដូវស្លឹកឈើលាស់លឹបលមួយពព្រិចភ្នែក និង រដូវស្លឹកឈើជ្រុះដ៏ខ្លីក្រញិច ។

នៅលើព្រលានយន្តហោះមានតែពួកយើងដែលជាកម្ពុជាចំនួន ៧០ នាក់តែប៉ុននោះ រួមទាំងកូនស្រីទាំងពីររបស់ខ្ញុំ និង ខ្ញុំផង ។ ពួកយើងទាំងអស់ព្តាស្លៀកពាក់ខោអាវខ្មៅ ដែលជាសំលៀកបំពាក់អ្នកតស៊ូ ហើយនៅជុំវិញយើងគឺមានចិនទាំងឡាយ ដែលមកជួនដំណើរយើង ។ ដើម្បី " ភ្ញៀវឧត្តុង្គឧត្តម " បែបពួកយើងនេះ ប្រទេសចិនបានជួលយន្តហោះពិសេសមួយតែម្តង ។

- សូមលា !

- អរគុណណាស់ ចំពោះជំនួយឧបត្ថម្ភដ៏កក់ក្តៅរបស់សមមិត្ត ។

- នេះគឺគ្រាន់តែជាភារកិច្ចរបស់យើងខ្ញុំតែប៉ុននោះ ។

ប៉ំនកប្រែពិតជាមិនបានសុក្រឹត ប៉ុន្តែសូមមិត្តអ្នកអានចាត់ថានេះគឺជាការសូមចូលរួមបូជាចំនេះដីងដ៏តិចតួចដែលខ្ញុំបាទមានទាំងប៉ុន្មានតបស្នងគុណទឹកដីនេះ ប្រជាជាតិនេះ និងមាតា (នាម ឡោ លាទហ៊ន) បិតា (នាម ខៀម ទន) របស់ខ្ញុំបាទដែលបានផ្តល់កំនើត ដួងព្រលឹង និង បង្ហាត់បង្ហាញរូបខ្ញុំបាទអោយជានិច្ចកាលស្រលាញ់ជាតិមាតុភូមិ ស្រឡាញ់សច្ចយុត្តិធមិ និង បំរើផលប្រយោជន៍រួម ។

ស្យៀវភៅនេះក៏ជាការរួមចំនែកផងដែររបស់ប្រពន្ធរបស់ខ្ញុំបាទនាម នេត រឡ៊ី ដែលក្រៅពីការងាររបស់ខ្លួន បានជួយអាន និង ស់រួលស់នៅដើមរបស់ខ្ញុំបាទ ។

ភ្នំពេញ ថ្ងៃទី ១៦ បិទុនា ១៩៨៧

ខៀម អាញ្ញារ៉ឌ្ឌ

- ស្ថ -

- សូមដណ្តើមបានជោគជ័យធំ១ ថែមទៀត ក្នុងការសាកល្បងសង្គម និយមណា !

- សូមលា !

យើងចេញដំណើរទៅប្រទេសកម្ពុជាហើយ ។ ពួកយើងគឺជាអ្នកដំបូង បង្អស់ដែលនឹងចេញទៅភ្នំពេញ ៦ ខែក្រោយពីថ្ងៃរំដោះ ១៧ មេសាមកនេះ ។ នៅលើរង្វង់មុខរបស់អ្នករួមដំណើរជាមួយខ្ញុំ គេអាចមើលឃើញនូវទឹកមុខ មោទនភាព និងការប្តេជ្ញាចិត្តដូច១ គ្នា ។

ជាការណែនាំ គឺសាក់កាដូម្នាក់ៗ ត្រូវតែស្រាលដោយហេតុនេះនៅ ក្នុងសាក់កាដូរបស់ខ្ញុំ មានមុងមួយ ភួយតូចមួយ សំពត់ និង អាវ មួយបន្លាស់ ថ្នាំដុសឆ្មេញ សាប៊ូ ស្ទីឡូមួយ ក្រដាសសរសេរមួយចំនួន រូបថតបួនសន្លឹក និង ម្ទុលវិទ្យាសាស្ត្រមួយចំនួនតែប៉ុនេះ ។ មុននេះអង្គការ * (១) បានស្នើ អោយទាំងអស់គ្នាប្រគល់នូវគ្រឿងអលង្ការ និងគ្រឿងមានតំលៃផ្សេងៗ ។ ខ្ញុំ បានប្រគល់ជូនអង្គការនូវអ្វីៗ ទាំងអស់ដែលខ្ញុំមាន : ខ្សែកមាសមួយខ្សែដែល ជាកេររបស់ជីដូនខ្ញុំដែល ទទួលតពីយាយទួតខ្ញុំ គ្រាប់គុជខ្សែកធ្វើពីក្វាតពណិជ្ជា កុលាបមួយខ្សែ មួយទៀតធ្វើពីដៃរគៀម (Ambre) ចិញ្ជៀនភ្ជាប់ពាក្យ (Alliance) ចិញ្ជៀន និងក្រវិល ។ ខ្ញុំបានប្រថុយខុសនឹងវិន័យដោយទុក

* (១) - *សញ្ញានេះសំគាល់ថាស្មេរបានប្រើភាសាខ្មែរនៅក្នុងស្យៀវភៅដើមរបស់ខ្លួន (កំនត់ អ្នកបកប្រែ - ក.អ.ប.)*

នាឡិកាដៃមួយបន្ថែមពីលើ នាឡិកាដែលខ្ញុំពាក់នៅនឹងដៃស្រាប់ ដោយថា នាឡិកានោះ គឺជាចំនងដៃចុង ក្រោយរបស់ឪពុកខ្ញុំនៅពេលខួបកំនើតទី ២១ របស់ខ្ញុំ ។

ខ្ញុំងាកសំលឹងមើលទៅខាងក្រោយ ។ ខ្ញុំប្រទះឃើញ *ស៊ីរីវុធ* ដែល ត្រូវជាបងប្ងួនជីដូនមួយរបស់ប្តីខ្ញុំ ហើយដែលកំពុងឈរខ្ជូរមុខនៅឯខាងក្រោយ គេ ។ ខ្ញុំធ្វើសញ្ញាទៅ *ស៊ីរីវុធ* ៗ ក៏ដើរមកជិត ។ ខ្ញុំក៏ប្រគល់លុយកាក់ដែល ខ្ញុំនៅសល់ទាំងប៉ុន្មានទៅអោយ :

-បន្តិចទៀត យើងនឹងជួបគ្នានៅឯភ្នំពេញណា !

-ដោយខំលាក់យ៉ាងលំបាកនូវចេតនារម្មណ៍របស់ខ្លួន *ស៊ីរីវុធ* បានពោល ប្រាប់ខ្ញុំនូវការសោកស្តាយរបស់ខ្លួន ដែលមិនបានរួមដំណើរជាមួយពួកយើង ។ ជាលេខាធិការទួត *វុធ* ត្រូវតែនៅឯប៉ែកាំងនេះ ។ *វុធ* អោនថើបកូនស្រីខ្ញុំទាំង ពីរ ។ ម្នាក់អាយុ បី ឆ្នាំ និងម្នាក់ទៀតអាយុ បួន ឆ្នាំ ស្លៀកពាក់ខ្មៅសក់កាត់ខ្លី និង ដោយស្តាយយ៉ាងហីនូវសាក់កាដូរបស់វាមួយម្នាក់នៅឯស្មាទៀតផងនោះ កូន ស្រីខ្ញុំទាំង ពីរ មើលទៅហាក់ដូចជាអ្នកតស៊ូខ្ជីល្ហក់ពិតៗ តែម្តង ។

- ពួកខ្ញុំទៅជួបប៉ាហើយ ។ ពួទៅលេងពួកខ្ញុំទេ ? - ពួកវានិយាយ ទៅកាន់ *ស៊ីរីវុធ* ។

ពេលដែលខ្ញុំរៀបឡើងជណ្តើរយន្តហោះ ស្រាប់តែអ្នកបកប្រែ សញ្ជាតិចិនម្នាក់ដែលខ្ញុំស្គាល់យ៉ាងច្បាស់ បានមកស្នើខ្ញុំអោយទៅជួបនឹងអ្នក

មុខអ្នកការម្ភាក់ដែលឈរឆ្ងាយពីនោះបន្តិច ។ គឺអនុប្រធានផ្នែកពិធីការ ។ គាត់និយាយឡើង ។

- ក្នុងនាមនាយករដ្ឋមន្ត្រី *ជូរអេនហ្សាយ* ខ្ញុំសូមជូនពរសូមសមមិត្តបានជោគជ័យទាំងស្រុង ។

ដោយភ្ញាក់ផ្អើលផង និង រំភើបផងចំពោះការយកចិត្តទុកដាក់ដ៏មានតំលៃ និង ដែលមិនបានគិតដល់ផងនេះ ខ្ញុំខំប្រមែប្រមូលបានពាក្យប៉ុន្មានឃ្លាដែរ ដើម្បីឆ្លើយតប :

- សមមិត្តបានបង្ហាត់បង្រៀនគ្រប់បែបយ៉ាងដល់ខ្ញុំ ។ សូមថ្លែងអំនរគុណចំពោះការទទួលរាក់ទាក់យ៉ាងកក់ក្តៅរបស់សមមិត្ត។ សូមអរគុណ។ សូមលោកនាយករដ្ឋមន្ត្រីជាទីស្រលាញ់រឆាប់បានមានសុខភាពល្អឡើងវិញ ។ សូមលោកប្រធាន *រម៉ី* មានអាយុយឺនយូរ ។ ខ្ញុំសូម ជូនពរ សូមសមមិត្ត និងសមមិត្តឯទៀត ដណ្តើមបានជោគជ័យកាន់តែធំធេងថែមទៀត .....។

មន្ត្រីផ្នែវការនេះនៅកាន់ ដៃខ្ញុំជាប់រហូត ក្នុងរយៈពេលសុន្ទរកថារបស់ខ្ញុំ ។ ខ្ញុំនិយាយចប់ គាត់ក៏ឧទ្ទានឡើង :

- យី សមមិត្តចេះនិយាយភាសាចិនច្បាស់ណាស់ ហ្ន៎!

ខ្ញុំហាក់ដូចជាដឹងថា មានអារម្មណ៍ឃ្លេងឃ្លោងដោយចេតនារម្មណ៍រំភើប ។ សេចក្តីសំរេចដែលខ្ញុំប្រកាន់យកនេះនឹងមានផលវិបាកច្រើន ។ រួចរំពេចនោះស្រាប់តែខ្ញុំមានការភ័យខ្លាចចំពោះមុខគ្រោះថ្នាក់ទាំងឡាយ ដែល

នៅរង់ចាំខ្ញុំ ។ ខ្ញុំស្ងាក់ស្ងើរមួយភ្លែតដែរ ។ បើសិនជាខ្ញុំឈប់មិនទៅវិញ ក៏ប្រហែលជាមិនទាន់ហួសពេលដែរទេមើលទៅ ? នៅឯប៉េកាំង ខ្ញុំសំរេចបានតួនាទីមួយដែរក្នុងសង្គម តែអីលូវនេះម៉េចក៏ខ្ញុំបែរជាបោះបង់ចោលវាជាថ្នូរនឹងពិសោធន៍មួយដ៏តឹងតែង ជាថ្នូរនឹងការរស់នៅដ៏លំបាកលំបិនក្នុងចំនោមមនុស្សដែលមានសតិអារម្មណ៍ចង្អៀត ហើយដែលធ្លាប់ធ្វើអោយខ្ញុំឈឺចាប់រួចមកហើយនោះទៅវិញអញ្ចឹង ? ។ ប៉ុន្តែខ្ញុំទប់អារម្មណ៍ទាន់ ហើយញញឹមទៅកាន់អ្នកជូនដំណើរខ្ញុំ :

- សូមអរគុណម្តងទៀត ។ ខ្ញុំសូមលាសិនហើយ



ខ្ញុំត្រូវទៅតាមប្តីខ្ញុំឈ្មោះ *ស៊ីរគ្យីន* នៅឯភ្នំពេញ ។ យើងបានស្គាល់គ្នាពីប្រាំពីរ ឆ្នាំមុននេះនៅឯប្រទេសបារាំង។ ពេលនោះគាត់ជានិស្សិត ឯខ្ញុំវិញធ្វើជាគ្រូបង្រៀន ។ គាត់តែងនិយាយប្រាប់ខ្ញុំប្រកបដោយមោទនភាពអំពីប្រទេសគាត់ ប្រជាជនគាត់ ។ គាត់បានពន្យល់ខ្ញុំថា ពួកបញ្ញាជនកម្ពុជាដ៏មានប្រជាប្រិយភាព បានរត់ចូលព្រៃដើម្បីបង្កើតសង្គមថ្មីមួយដែលពោរពេញទៅដោយយុត្តិធម៌ និងសមភាព ។ តំបន់រំដោះត្រូវបានពង្រីកឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយកសិករទាំងឡាយបានធ្វើជាម្ចាស់ជោគវាសនាខ្លួន ជីវភាពរស់នៅកាន់តែ

ល្អប្រសើរ ដោយរួចចាកផុតពីការជិះជាន់ និង កេងប្រវ័ញ្ចទាំងអស់ ។ បង *ស៊ីគឿន* ស្រលាញ់ប្រទេសនិងប្រជាជនខ្លួនណាស់ ។ គាត់បានណែនាំខ្ញុំអោយស្គាល់មិត្តភ័ក្តិនានារបស់គាត់ ។ គេទាំងនោះសុទ្ធតែមានទំនុកចិត្តចំពោះអនាគតប្រទេសខ្លួន ហើយបានបូជាអ្វី ១ ទាំងអស់ដើម្បីគោលដៅនេះ ។

លុះដល់ថ្ងៃ ១៨ មិនា ១៩៧០ ពេលដែលមានរដ្ឋប្រហារទំលាក់ព្រះអង្គម្ចាស់ *សីហនុ* បង *ស៊ីគឿន* បានសំរេចចិត្តភ្លាមថា ចេញដំណើរទៅប៉េកាំង ដើម្បីវាយតំលៃវិវត្តន៍នៃសភាពការណ៍អោយបានក្បៀក ។ គាត់មានគំរោងថានឹងទៅរួមការតស៊ូថ្មីនៅក្នុងជួរទ័ពព្រៃ ។ ថ្ងៃ ៧ កក្កដា ក្នុងពេលវិស្សមកាល ខ្ញុំក៏បានចាកចេញពីប្រទេសបារាំង ដើម្បីទៅតាមប្តីខ្ញុំ នៅឯប៉េកាំងដែរ ។

តាំងពីនៅកុមារភាព ប្រទេសចិនតែងធ្វើអោយខ្ញុំស្រមើស្រមៃ ។ ពិភពដ៏អស្ចារ្យនេះតែងតែខាបឆក់ព្រលឹងខ្ញុំជានិច្ច ប៉េកាំង វិមានរដូវក្តៅ ប៊ុរីហាមឃាត់ (១) មហាកំពែង... ខ្ញុំជ្រួលចិត្តនឹងកំនាព្យ ទស្សនវិជ្ជា គំនូស សញ្ញាចិន ....

ឱ ! ការសប្បាយរីករាយរបស់ខ្ញុំ គ្មានក៏រឹតព្រំដែនទេ នៅពេលនោះ ។

ប៉ុន្មានថ្ងៃក្រោយពីខ្ញុំទៅដល់ប៉េកាំង ខ្ញុំត្រូវបានគេអញ្ជើញទៅក្នុងពិធីបដិសណ្ឋារកិច្ចចំពោះការវិលត្រលប់របស់ *សីហនុ* ពី កូរេ វិញ ។ ដោយគ្មានដឹងអ្វីបន្តិចបន្តួចសោះពីពិធីការទាក់ទិននឹងប្រមុខរដ្ឋ ពិសេសបដិសណ្ឋារកិច្ច

(១) *ព្រះរាជវាំងចិន ភាគខាងក្នុង (ក.អ.ប.)*

ព្រះអង្គម្ចាស់ថៃមទ្បៀតនោះ ខ្ញុំក្អូងទំលាប់ជាស្រីបារាំងផង ក៏មិនបានគោរពពេលម៉ោងឡើយ ។ ខ្ញុំក៏ទៅដល់ស្ថានីយរថភ្លើងដោយយឺតយ៉ាវ ធ្វើអោយឆ្លើលអស់សហគមន៍ខ្មែរនៅទីនោះ ។ ខ្ញុំនៅឈរស្ទឹលើតែមផ្លូវដែកដោយភ្លឺកនឹងភាពច្របាត់ច្របែងនៃឡានផ្លូវការផង ចលនាហ្វូងមនុស្សផង ។ រំពេចនោះខ្ញុំឃើញមនុស្សម្នាក់ មានចិញ្ចើមក្រាស់ឃ្មឹក លេចចេញនៅមុខខ្ញុំតែម្តង : គឺ *ដូ អេនឡាយ* ។ ខ្ញុំឡើងស្រលាំងកាំងអស់ ។

- សូមស្វាគមន៍ ! សូមស្វាគមន៍ ! - គាត់និយាយមកខ្ញុំជាភាសាបារាំងបណ្តើរហុចដៃមកខ្ញុំបណ្តើរ ។

នៅចុងបញ្ចប់នៃរដូវក្តៅ ខ្ញុំបានសំរេចចិត្តថាមិនត្រលប់ទៅប្រទេសបារាំងដើម្បីបន្តការរៀនសូត្រ និងប្រកបការងារដែលគ្មានន័យអ្វីទៀតចំពោះខ្ញុំនោះទេ ។ ខ្ញុំបានសំរេចចិត្តរស់នៅក្បែរប្តីរបស់ខ្ញុំ ដើម្បីរួមចំនែកក្នុងការប្រឹងប្រែង និងក្នុងឆន្ទៈក្លៀវក្លារបស់គាត់ផង ដើម្បីស្គាល់ថៃមទ្បៀតពីប្រទេសចិនដែលយើងត្រូវបង្កំចិត្តស្នាក់អាស្រ័យនៅនេះផង ។

ប៉ុន្តែអនិច្ចាអើយ ! ឆន្ទៈក្លៀវក្លារបស់ខ្ញុំ ត្រូវទាបចុះក្នុងរយៈពេលយ៉ាងខ្លី ។ ការរស់នៅរបស់ខ្ញុំនៅក្នុងសហគមន៍ខ្មែរ គឺសែនលំបាក ។ សន្ទុះស្នេហាជាតិបានធ្វើអោយមិត្តនិរទេសរួមរបស់ខ្ញុំ ក្បៀសខ្ញុំចេញពីកង្វល់ និងសកម្មភាពនានារបស់ពួកគេ ។ អារម្មណ៍នេះកាន់តែពោរពេញឡើងនៅពេលដែល *អៀង សារី* ក្នុងឋានៈជាប្រេសិតពិសេស នៃចលនាតស៊ូក្នុងស្រុកបានមកដល់

ប៉ែកាំង ។ ពេលនោះខ្ញុំកំពុងពរពោះកូនដំបូងផង ។ *អៀង សារី* បានទាមទារ អោយដកខ្ញុំចេញផុតពីសកម្មភាពនានារបស់សហគមន៍កម្ពុជា ដោយប្រកាសយ៉ាងម៉ឺងម៉ាត់ថា :

- រឿងរ៉ាវកម្ពុជា ទាក់ទិនតែជនជាតិកម្ពុជាទេ ។

តាំងពីពេលនោះមក គេសំលឹងមើលមកខ្ញុំហាក់ដូចជាអ្នកជ្រែករំខានគេ ជាចារនារី ជាខ្មោចព្រាយទារពៃរតែអញ្ចឹង ។ ខ្ញុំសាកល្បងដោយឥតបានលទ្ធផលអ្វីទាំងអស់ដើម្បីតវ៉ា ដើម្បីការពារខ្លួន ។ ខ្ញុំខំអះអាងពីសុច្ឆន្ទៈរបស់ខ្ញុំ ប៉ុន្តែ គ្មានបានការអ្វីទាំងអស់ ទីបំផុតខ្ញុំក៏ផ្ទុះចេញនូវការខកចិត្តរបស់ខ្ញុំដោយលាន់មាត់ថា :

- ចុះអីក៏គំនិតចង្អៀតចង្អល់ម្លេះ !

សំដីនេះធ្វើអោយ *អៀង សារី* លេបមិនចូលទេ ហើយមនុស្សនេះក៏គុំខ្ញុំរហូត ។ *អៀង សារី* ហាមឃាត់មិនអោយខ្ញុំបន្តលិខិតឆ្លងដែនជាថ្មី រួចឃាឃាំងខ្ញុំមិនអោយចុះសំបុត្រកំនើតកូនស្រីខ្ញុំ ក្នុងបញ្ជីអត្រានុកូលដ្ឋានបារាំង (១) ថែមទៀត ។

នៅចំពោះមុខការរកឿងរករ៉ាវយ៉ាងនេះ ខ្ញុំពូនខ្នុរតែម្នាក់ឯងហើយរស់នៅក្នុងស្ថានភាពឯកោយ៉ាងយូរ គ្មានទំនាក់ទំនងជាមួយមាតុប្រទេស ទាំង

(១) តាមច្បាប់បារាំង ចំពោះជនជាតិបារាំងដែលមានប្តី វី ប្រពន្ធបរទេសនៅពេលមានកូន ១ នេះ អាចមានសញ្ជាតិបារាំងផង អាចមានសញ្ជាតិរបស់ប្រពន្ធ វីប្តីជាបរទេសនោះបានផង (ក.អ.ប)

ជាមួយសហគមន៍របស់ប្តីខ្ញុំ ។ ប៉ុន្តែខ្ញុំក៏មិនបាននៅដេកស្តីកនោះដែរ ។ ខ្ញុំក៏បានចាប់រៀនភាសាចិន ។ ប្រការនេះបានធ្វើអោយខ្ញុំអាចកសាងបាននូវទំនាក់ទំនងជាទីលួងលោមចិត្តដ៏កក់ក្តៅជាមួយសមមិត្តនានា ដែលនៅជុំវិញខ្ញុំនោះ ។

កំនើតកូនស្រីទីពីរ របស់ខ្ញុំ ក៏មិនបានបង្ខិតខ្ញុំទាំងទៅជិតសហគមន៍ខ្មែរ ទាំងទៅជិតប្តីខ្ញុំឡើយ ។ អត្ថភាពខ្ញុំ វត្តមានខ្ញុំគឺជាកំបង់ចាញ់របស់គាត់ចំពោះមុខជនរួមជាតិរបស់គាត់ ។ ស្ថានភាពនេះស្ថិតនៅរហូតដល់ពេលដែលគាត់ត្រូវបានអនុញ្ញាតអោយទៅតស៊ូឯក្នុងស្រុក ។ ពេលនោះទើបអាកប្បកិរិយារបស់គាត់ និង ជនជាតិកម្ពុជាឯទៀតចំពោះខ្ញុំមានបំលាស់ប្តូរទាំងស្រុងតែម្តង ។ ពេលដឹងដំណឹងថាគាត់ត្រូវទៅរួមការតស៊ូនៅឯក្នុងប្រទេសនោះ ខ្ញុំបានសំដែងការសប្បាយរីករាយចិត្ត ហើយគេក៏បានសំដែងការស្ងប់ស្ងែងចំពោះបញ្ហានេះ ។ គេលើកសរសើរពីសេចក្តីក្លាហានរបស់ខ្ញុំ ហើយខ្ញុំក៏ស្រាប់តែឃើញគេទទួលរាក់ទាក់ខ្ញុំយ៉ាងរហ័ស ដូចកាលពីគេបញ្ជូញខ្ញុំពីមុនអញ្ចឹងដែរ ។ ហើយចាប់ពីពេលនោះមកហើយ ទើបឆ្នាំចុងក្រោយនៃការស្នាក់នៅក្នុងប្រទេសចិនបានប្រព្រឹត្តទៅក្នុងបរិយាកាសល្អជាងមុន ។ ខ្ញុំបានធ្វើដំណើរដ៏វែងឆ្ងាយ ពីរ ដង ។ ម្តងតាមទិសខាងលិចរហូតដល់ យេណាន និង ម្តងទៀតតាមទិសខាងត្បូងរហូតដល់ កង់តុង (កន្តាំង) ។ ក្នុងដំណើរនេះខ្ញុំមានអនុស្សាវរីយ៍ដ៏រស្មារ្យ ។ គ្រប់ទីកន្លែងខ្ញុំបានជួបប្រទះនូវបរិយាកាសធូរស្រាល និងភាពដ៏សែនស្វាហាប់ក្នុងពលកម្មដូច ១ គ្នា ។ ខ្ញុំកំពុងតែទស្សនាការក្រោកឡើងរបស់

ប្រជាជនសាមញ្ញមួយ ដែលចាំងចិញ្ចែងដោយមោទនភាពដ៏ល្អស្រស់ ។ មនុស្ស និង ធម្មជាតិហាក់ដូចជាស៊ីចូលគ្នាម៉ែនទេ ។ មនុស្សបានពង្រឹងភាពធ្វើម្ចាស់លើធម្មជាតិ និងលើធម្មជាតិជាមនុស្សរបស់ខ្លួន ។ នេះជាការរីកឡើងនូវពិភពថ្មីមួយ ។ ខ្ញុំបានមានចិត្តស្រលាញ់ប្រទេសចិន ដែលចេញផុតពីបដិវត្តន៍វប្បធម៌ប្រកបដោយកំលាំងថ្មីស្រលាងនោះយ៉ាងជក់ចិត្ត ។

ពេលនោះខ្ញុំភ្លេចអស់ហើយកំហកចិត្តទាំងប៉ុន្មានរបស់ខ្ញុំ ហើយខ្ញុំព្យាករអនាគតរបស់ខ្ញុំយ៉ាងនឹងន ។

នាថ្ងៃ ១៧ មេសា ១៩៧៥ ពីជាការចំលែកមួយដែលដំណើរស្តីពីការរំដោះទីក្រុងភ្នំពេញបានកន្ត្រាក់ ទឹកចិត្តរីករាយតែបន្តិចបន្តួច តែប៉ុននោះនៅក្នុងចំនោមពួកខ្មែរនិរទេសនៅក្នុងទីក្រុងប៉េកាំង ។ មានអ្នកខ្លះក៏បានរៀបចំវិលត្រលប់ទៅប្រទេសខ្លួនវិញ តែក៏មានអ្នកខ្លះរៀបចំដើម្បីបន្តការនិរទេសរបស់គេនោះទៅក្រោមផ្ទៃមេឃផ្សេងទៀតដែរ ។ ខ្លួនខ្ញុំផ្ទាល់ក៏រារែកដែរ ។ ខ្ញុំហាក់ដូចជាចង់បន្តការស្នាក់អាស្រ័យរបស់ខ្ញុំ នៅក្នុងប្រទេសចិន ដែលជាកន្លែងដែលខ្ញុំត្រូវបន្តរៀនសូត្រច្រើនតទៅទៀត ។ ម្យ៉ាងទៀតនៅក្នុងជំរៅនៃដួងចិត្តខ្ញុំ ។ ហាក់ដូចជាចូលចិត្តមិត្តភាពរបស់ចិន ជាងទំនាក់ទំនងដែលភាគច្រើនជាទំនាក់ទំនងដ៏លំបាកដែលខ្ញុំមានជាមួយពួកជនជាតិរបស់ប្តីខ្ញុំផង ។

ជាក់ស្តែងសហគមន៍ខ្មែរត្រូវនៅគាំងស្ទះជាច្រើនខែ នៅឯប៉េកាំងដោយអង្គការ * បានពន្យាររាល់ការចេញដំណើរទាំងអស់ ។

ខ្ញុំតែងតែដណ្តើងសួរខ្លួនឯងជាញឹកញាយ អំពីអ្វីដែលនៅលាក់បំពួនពីក្រោយនាមពេញដោយមហិទ្ធិរិទ្ធិ និងដ៏សែនគោរពនៃអង្គការ * នេះ ។ តើអង្គការនេះមានន័យយ៉ាងម៉េចទៅ ? គ្មានអ្នកណាម្នាក់ដឹងច្បាស់លាស់ឡើយ ។ អ្នកខ្លះនិយាយថាអង្គការនេះគឺតំនាងអោយបក្សកុំមុយនីស រឺ បក្សសង្គមនិយម ។ អ្នកខ្លះទៀតថា នេះគឺជាក្រុមដឹកនាំសមូហភាពមួយ ។ ឯអ្នកខ្លះទៀតអះអាងថានេះគឺជាតំនាងនូវអំនាចរបស់វរជនដ៏ឆ្នើមម្នាក់ ។

រដូវក្តៅឆ្នាំ ១៩៧៥ ត្រូវបានកត់សំគាល់ដោយការមកសួរសុខទុក្ខរបស់ម្តាយខ្ញុំនិងការវិលត្រលប់របស់ប្តីខ្ញុំ ។ ខ្ញុំជួបប្តីខ្ញុំនៅថ្ងៃទី ១៥ សីហា ក្នុងឱកាសបដិសណ្ឋារកិច្ចផ្លូវការមួយ ដែលបានរៀបចំឡើងក្នុងឱកាសទស្សនកិច្ចរបស់ *ខៀវ សំផន* ។ បង*ស៊ីវគឿន* ប្រែប្តូរច្រើនណាស់ ។ ពីមនុស្សម្នាក់ដែលមានក្បាលពោះបន្តិច គាត់បានប្រែទៅជាមនុស្សស្គមកំព្រឹងមួយ ។ គាត់មិនពាក់វ៉ែនតាទៀតទេ ហើយដល់អញ្ចឹងទៅ ភ្នែតតែធ្វើអោយមុខគាត់ដែលមានថ្ពាល់ផត និងភ្នែករួងនោះឃើញរីតតែស្តួមថែមទៀត ។ មើលទៅហាក់ដូចជាគាត់ទើបរស់រានចេញផុតពីជំរុំប្រមូលផ្តុំអញ្ចឹង ។ តើគាត់ត្រូវរងល់បាកវេទនាយ៉ាងណានៅក្នុងពេលដែលខ្ញុំរស់នៅយ៉ាងសុខស្រួលនៅឯប៉េកាំងនោះ ? គំនិតនេះធ្វើអោយខ្ញុំចុកចាប់ជាពន់ពេក ។ ខ្ញុំមានអារម្មណ៍ថា ខ្លួនឯងមានកំហុសព្រោះតែមិនបាននៅជិតប្តី មិនបាននៅជួយគាំទ្រប្តីសោះឡើយ ។

នៅពេលដែលយើងជួបគ្នា បង*ស៊ីវគឿន* បាននិយាយក្រាប់ខ្ញុំពីបដិវត្តន៍

ដែលកំពុងតែដំណើរការនៅឯកម្ពុជា ។ គាត់បានរ៉ាយរ៉ាប់ពីជីវភាពថ្មីនោះដល់ខ្ញុំ ។ មនុស្សម្នាទាំងឡាយរស់នៅយ៉ាងសុខដុមរមនាដោយផលនៃពលកម្មរបស់ខ្លួន។ គ្មានអ្នកជិះជាន់ហើយក៏គ្មានអ្នកដែលត្រូវគេជិះជាន់ទៀតដែរ ។ លុយកាក់ត្រូវបំបាត់ចោល ។ ឧក្រិដ្ឋកម្មក៏ដូចជាពេស្យាកម្ម និងក៏ដូចជាជំងឺសង្គមផ្សេងៗ ទៀតដែរសុទ្ធតែបានរលាយបាត់រូបទាំងស្រុង ។ នៅស្រុកខ្មែរគ្មានទុរភិក្ស គ្មានអត់ការងារធ្វើឡើយ ។

ក្នុងពេលស្តាប់គាត់និយាយពីរឿងរ៉ាវទាំងនេះ ខ្ញុំទើបមើលឃើញមនុស្សថ្មីមួយ ។ គាត់នឹងធឹង ហើយហាក់ដូចជារីកថ្កោលឡើង នេះបើកុំនិយាយដល់ភាពចំអឹងរបស់គាត់ ។ ចេញផុតពីកង្វល់បារម្ភយ៉ាងនេះ បង*ស៊ីគ្វីន* ហាក់សំរេច " កសាងខ្លួន " បាន បើនិយាយតាមភាសាបដិវត្តសម័យនោះ ។ គាត់និយាយប្រាប់ខ្ញុំថា ÷

- នៅកម្ពុជា យើងបន្ត នឹងធ្វើអោយកាន់តែស៊ីជំរៅនូវបទពិសោធន៍របស់ចិន ហើយពួកយើងត្រូវការអ្នកឯងណាស់ !

គេត្រូវការខ្ញុំ ? អញ្ចឹងខ្ញុំអាចមានប្រយោជន៍ខ្លះដែរឬ ? បង*ស៊ីគ្វីន* ទើបចាក់ចំចំនុចខ្សោយរបស់ខ្ញុំតែម្តង ។ មួយរំពេចនោះ ខ្ញុំភ្លេចអស់រឿងរ៉ាវពីមុន ១ មក ។ អនុស្សាវរីយ៍អាក្រក់ទាំងប៉ុន្មានរបស់ខ្ញុំ ប៉ើងរលត់រលាយខ្លាត់ខ្លាយខ្ចេចខ្ចី ។ អនាគតបើកឃ្វាំងយ៉ាងត្រចះត្រចង់នៅពីមុខយើងប្រៀបបីដូចជាថ្ងៃដំបូងដែលយើងបានជួបគ្នាអញ្ចឹង ។ ទាំងពីរនាក់យើងនឹងអាចចូលដៃគ្នា

រួមចំនែកក្នុងការរីកលូតលាស់របស់មនុស្សជាតិបានហើយ ។

បង*ស៊ីគ្វីន* ធានាអះអាងថា បើសិនជាខ្ញុំទៅកម្ពុជា អង្គការនឹងយកចិត្តទុកដាក់ធ្វើយ៉ាងណាអោយកូនស្រីខ្ញុំ និងខ្ញុំអាចរស់នៅក្នុងលក្ខខណ្ឌដ៏ល្អ ។ ដូចនេះខ្ញុំក៏បានសំរេចចិត្តចេញដំណើរទៅតាមប្តីខ្ញុំ ។ ខ្ញុំមានអារម្មណ៍ហាក់ដូចជានៅមាត់ច្រកនៃការផ្សងព្រេងដ៏អស្ចារ្យ និងនៃពិសោធន៍មួយដ៏ធំធេងដែលអាចថាមិនដែលមានសោះឡើយ ។ មិនមែនគ្រាន់តែខ្ញុំទៅចូលរួមក្នុងបដិវត្តន៍សង្គមមួយប៉ុណ្ណោះទេ ប៉ុន្តែគឺទៅចូលរួមក្នុងការសាកល្បងបំប្លែងមនុស្សថែមទៀត ។

ពេលគឺកាលនោះខ្ញុំនឹកស្មានអញ្ចឹង នៅពេលដែលខ្ញុំចូលទៅក្នុងយន្តហោះទៅភ្នំពេញនៅព្រឹកនោះ ។



ក្រោយពីការហោះហើរចំនួន បួនម៉ោងមក នារីបំរើក្នុងយន្តហោះបានអោយដំណឹងថា យើងហោះពីលើប្រទេសកម្ពុជាហើយ ។ អ្នកដំណើរដ៏រីករាយបានទះដៃប្រាវស្ទើរបែកយន្តហោះ ។ យន្តហោះហោះតាមបណ្តោយទន្លេមេគង្គ ។ ពេលនេះ គឺជាចុងរដូវភ្លៀង ហើយទិដ្ឋភាពដាច់កន្ទុយភ្នែកគ្របលិចទៅក្នុងទឹក ។ អ្នកដំណើរក៏ប្រជ្រៀតផ្ទុំគ្នាតាមបង្អួចយន្តហោះ និងរត់ពីម្ខាង

ទៅមួាង ដើម្បីមើលទំនប់ឯនេះ មើលប្រព័ន្ធភ្លឹងនោះ ។ អ្នកបើកយន្តហោះ ដោយររស់ សំនើចនឹងភាពរ៉ភើបរីករាយនេះ ក៏ជួយផ្ទៀងផ្ទងម្តងទៅខាងនេះ ម្តងទៅខាងនោះ ។ ម្នាក់ៗប្រជែងសំដែងទឹកចិត្តក្ស្យៀវក្លារបស់ខ្លួន ហើយ សំដែងឆន្ទៈស្នេហាជាតិខ្លួន ក្នុងការចូលរួមយ៉ាងឆាប់រហ័សក្នុងការកសាងទំនប់ រឺ ជីកព្រែករ្យៀងៗ ខ្លួន ។

ពេលយើងមកដល់ភ្នំពេញ យន្តហោះបានហោះឆ្ងែលពីរជុំមុននឹងចុះ ។ ខ្ញុំសំលឹងមើលដោយស្ងើចសរសើរនូវដំបូលទីកមាសនៃព្រះរាជវាំងដែលចាំងឆ្លុះ នឹងពន្លឺព្រះអាទិត្យ ។ ខ្ញុំភ្ញាក់នឹងទំហំដ៏តូចរបស់ទីក្រុងនេះដែរ ។ ជាការពិត ហើយថានេះមិនមែនជាប៉ារី រឺ ប៉ែកាំងទេ ប៉ុន្តែភ្នំពេញជះចេញពន្លឺប្រៀបដូចជា ដុំរតនៈ នៅក្នុងប្រអប់ព្រៃព្រឹក្សាដ៏ខ្សៀវស្រងាត់ ។ ខ្ញុំស្រមៃគិតថា មនុស្សម្នា ប្រហែលជារស់នៅកន្លែងនេះដូចជានៅក្នុងគ្រួសារធំមួយអញ្ចឹង ។

អីលូវនេះ ខ្ញុំភ្លេចប៉ែកាំង និង ប៉ារី បាត់ទៅហើយ ។ អនាគតរបស់ខ្ញុំ នៅក្រោមក្រសែភ្នែក ក្រោមជើងខ្ញុំនេះ ។ ខ្ញុំសែនសប្បាយរីករាយនៅពេល ដែលគិតថាខ្ញុំនឹងបានជួបប្តី ។ ជាមួយនឹងកូនស្រីទាំង ពីរ របស់យើង យើងនឹង ចាប់ផ្តើមកសាងជីវិតមួយពោរពេញទៅដោយសុភមង្គល ជាជីវិតដ៏មានប្រយោ ជន៍ និងប្រកបដោយសប្បុរសធមិ ។

នៅពេលដែលយន្តហោះឈប់ស្ងៀម និងពេលដែលសំលេងរេអាក់ទ័រ រលត់បាត់ហើយនោះ សញ្ចេតនាចំលែកមួយបានមករួបរឹតខ្ញុំ ។ មិត្តភ័ក្តិដែលធ្វើ

ដំណើរមកជាមួយខ្ញុំនោះស្រាប់តែក្លាយជាស្ងាត់ស្ងៀមឈឹងមួយរំពេច ។ ជា មួយអ្នកឯទៀត ខ្ញុំប្រញាប់ប្រញាល់ដើរទៅកាន់ទ្វារចេញ ។ នៅលើព្រលាន គ្មានមនុស្សម្នាក់សោះ ។ ខ្ញុំខំបើកភ្នែកសំលឹងរកមើលប្តីខ្ញុំ ។ គ្មានមនុស្សម្នា ទាំងអស់ គ្មានស្មីកំរើកបន្តិចណាសោះនៅលើព្រលានបេតុង ដ៏ស្ងាត់ជ្រងំដែល នៅមានសល់តែគំនរឆ្អឹងយន្តហោះដែលឆេះ ដែលរហែកធ្លាយមួយគរនៅ ឡើយដែលជាអនុស្សាវរីយ៍ចុងក្រោយនៃការប្រយុទ្ធ ។ សង្ត្រាមហាក់ដូចជា នៅមាននៅឡើយ ក្នុងស្ថានភាពឆ្គឹងដូចជារូបថតចុងក្រោយដែលអ្នកឆ្លើយឆ្លង បរទេសបានបញ្ជូនទៅក្រៅមុនពេលដែលភ្នំពេញរលំចុះអញ្ចឹង ។ ពេលចេញពី យន្តហោះ យើងបានដើរតំរង់យ៉ាងស្ងៀមស្ងាត់ ទៅកាន់ស្ថានីយ៍អាកាសចរ ។ សាលធំទទេស្អាតស្ងាត់ជ្រងំ ។ ខ្ញុំមានអារម្មណ៍ហាក់បីដូចជាចុះលើពិភពមួយ ដែលគ្មានជីវិតអញ្ចឹង ។ យើងស្ទើរមិនហ៉ានដកដង្ហើមហើយក៏គ្មានអ្នកណាម្នាក់ ហ៉ានកំរើកក៏ទេដែរ ។ ខ្ញុំខ្លាចរន្ទត់ផងសង្ស័យផង ។ ខ្ញុំសំលឹងមើលពួកក្រុម អាកាសយានិកចិន ឃើញពួកគេញញឹម ។ ប្រការនេះធ្វើអោយខ្ញុំកក់ក្តៅឡើង វិញ ។ រំពេចនោះ មនុស្សម្នាក់មិនដឹងជាលេចចេញពីកន្លែងណាមកទេបានដើរ តំរង់មករកក្រុមយើង ។ ខ្ញុំស្គាល់គាត់ភ្លាម ។ គឺជា*ស៊ីរិន* ជាមិត្តម្នាក់របស់ប្តីខ្ញុំ ។ ខ្ញុំញញឹមដាក់ *ស៊ីរិន* ហើយដើរតំរង់ទៅរកគាត់ ដោយលូកដៃទៅផង ។ *ស៊ីរិន* ធ្វើជាមិនដឹង ហើយ ដោយគ្មាននិយាយស្ងាគមន៍អ្វីមួយមាំត់សោះ គេបញ្ជា អោយពួកយើងឡើងឡានអ្នកដំណើរមួយដែលនៅរង់ចាំខាងក្រៅ ។ គេបាន

ប្រាប់បន្ថែមថា ហាមមិនអោយនិយាយក្នុងពេលធ្វើដំណើរនេះ។ យើងដើរយ៉ាងស្ងាត់ស្ងៀមទៅតាមទិសដែលគេបានប្រាប់យើង។ ឡានដឹកអ្នកដំណើរដ៏កញ្ជាស់ កំពិតកំពាវ និងមានពណ៌ប្រតេកប្រតាកមួយនៅរង់ចាំយើងនៅខាងក្រៅ។ យើងរកកន្លែងអង្គុយរួចរាល់ហើយ ឡានក៏ចេញដំណើរទៅទាំងរខេករខាក ។ កូនខ្ញុំទាំងពីរ ទារកឪពុកវា ។ ខ្ញុំប្រាប់ពួកវាថាប្រហែលជាឪពុកវាជាប់រវល់ការងារហើយ។ ប៉ុន្តែនៅក្នុងខ្លួនខ្ញុំផ្ទាល់ ខ្ញុំដឹងថា ការភ័យខ្លាចនិងភាពងកោកំពុងតែជ្រួលមកគ្របដណ្តប់ខ្ញុំសន្សឹមៗ ហើយ ។ មិនមែនជាភាពងកោធម្មតានោះទេ ប៉ុន្តែជាភាពងកោគ្មានរូបគ្មានរាង ដែលកក្រើករំពើងដែលច្បាមចាប់យើង ហើយអូសទាញយើងចាកចេញពីលោកនេះផុតពីពេលនិង លំហ (temps et espace) ។

តើមានរឿងអ្វីទៅ? ហេតុអ្វីក៍ *ស៊ីរិន* មិនព្រមនិយាយស្តីជាមួយខ្ញុំ? តើគ្រាន់តែពាក្យពោលស្វាគមន៍នោះ វាប្រឆាំងបដិវត្តន៍ រឺ ? បន្តិចម្តងៗ ការភ័យខ្លាចរបស់ខ្ញុំកាន់តែលេចរូបរាងច្បាស់ឡើងៗ ខ្លាំងឡើងៗ ។ ខ្ញុំហាក់ដូចជា ឃ្លាតចេញពីពិភពនេះអញ្ចឹង ។ នៅសងខាងផ្លូវមានរបងឡានដែលត្រូវគេទុកចោលតាមបណ្តោយផ្លូវ ក្នុងស្ថានភាពដូចនៅពេលដែលម្ចាស់របស់វាបានបោះវាយ៉ាងរហន់ដដែល ។ ផ្ទះទាំងឡាយនៅតំបន់ជាយក្រុងស្ងាត់ជ្រងំគ្មានមនុស្សម្នាក់ឡើយ ។ ទ្វារ និង បង្អួច ចំហធ្លុង ឯខាងក្នុងងងឹតឈឹងហាក់ដូចជាផ្ទះខ្មោច ។ នៅក្នុងទីធ្លាមុខផ្ទះ ក៏ដូចជានៅលើចិញ្ចើមថ្នល់ គេប្រទះឃើញនូវ

វត្ថុដែលត្រូវគេបោះបង់ចោលនៅរាយប៉ាយច្រលំបល់ដូចជាចានក្បាន ឆ្នាំង ពុទ្ធ ចង្ក្រាន ទូទឹកកក ពោលគឺគ្រប់សំភារៈប្រើប្រាស់ប្រចាំថ្ងៃដែលត្រូវគេបោះចោលតែពាសក្នុងពេលចាកចេញ និង ក្នុងពេលរើកកាយ ។ គ្មានមនុស្សម្នាក់ គ្មានឆ្កែ គ្មានសត្វស្លាប សូម្បីតែផ្កាមួយទងក៏គ្មានដែរ ។ ពិភពក្រលាប់ចាក់នេះហាក់ដូចផុសចេញត្រង់ៗ ពីសុបិនដ៏អាក្រក់មួយ ហាក់ដូចជាជីវិតទាំងអស់ត្រូវកំទេច និង បើ្ងរលាយបាត់ដោយកំលាំងដ៏ខ្លាំងគំហុកមួយដោយគ្រោះធម្មជាតិមួយដូចនោះឯង ។

សូម្បីតែរោងចក្រ និងឃ្លាំងផ្សេងៗ ក៏ត្រូវខ្ចេចខ្ចាំ និង បោះបង់ចោលដែរ ។ រំពេចនោះស្រាប់តែមានសំរែកមួយបានលាន់ឡើងនៅក្នុងរថយន្ត ។ គឺ *ជីណា* ដែលបានប្រទះឃើញផ្ទះរបស់ខ្លួន ។ នាងក្រោកឈរហើយស្រែកហៅញាតិមិត្តគ្រួសារនាង បួនស្រីនាង ម្តាយនាង មិត្តភក្តិនាង .... រួចនាងក៏អង្គុយចុះដោយស្រលាំងកាំង ។ រថយន្តនៅបន្តរត់ទៅមុខ។ ខ្ញុំក្រលេកទៅឃើញផ្ទះដ៏ធំមួយដែលនៅ មានលក្ខណៈបង្ហាញពីភាពស្តុកស្តម្ភរបស់ម្ចាស់ចាស់របស់វានៅឡើយ។ ដូចជានៅកន្លែងឯទៀតដែរ នៅទីនេះអ្វីៗ ត្រូវបោះបង់ចោលរាយប៉ាយ ។ ជញ្ជាំងដែលមានប្រហោងងងឹតឈប់ ស្ថិតនៅស្ងាត់ស្ងៀមឈឹង ហើយហាក់ដូចជាកួតដាក់ទីធ្លាមុខផ្ទះនូវរបស់របរប្រើប្រាស់រាប៉ាត់រាប៉ាយ ហើយដែលមួយចំនួនមានស្មៅដុះទ្រុបទ្រុលគ្របបាត់ទៅហើយ ។

ទិដ្ឋភាពនេះគួរអោយរន្ធត់ណាស់ ។ យើងទាំងអស់គ្នានៅក្នុងឡាននាំ

គ្នាងាកមុខចេញដើម្បីឈប់ឃើញអ្វីទៀតទាំងអស់ ។ យើងត្រូវប្រឹងទប់ទល់នឹងគំនិតទាំងឡាយដែលវាយសំរុកមកលើយើង ព្រោះគេតែងបង្ក្រៀនយើងនៅក្នុងវគ្គអប់រំនយោបាយជាច្រើនថាមិនអោយសង្ស័យ មិនអោយរិះគន់ មិនបណ្តោយអោយសតិអារម្មណ៍រវើរវាយឡើយ ។

ខ្ញុំខំប្រឹងលួងខ្លួនឯងថា ល្ងាចនេះខ្ញុំនឹងស្ថិតនៅឆ្ងាយពីទិដ្ឋភាពនិងស្ថានភាពនេះ ខ្ញុំនឹងស្ថិតក្នុងពិភពមួយដ៏ស្ងប់ស្ងៀម ដ៏សប្បាយនិងរស់រវើក អមពន្ធដោយប្តីខ្ញុំ និងកូនស្រីទាំង ពីររបស់ខ្ញុំ ។ ខ្ញុំមានបំនងបំភ្លេចអោយបានរហ័សនូវពិភពខ្មោច និង ក្រលាប់ចាក់នេះ ។

ប៉ុន្តែ រថយន្តបានមកឈប់នៅទីធ្លានៃអាគារដ៏ធំមួយដែលពីមុនជាទីស្នាក់ការនៃនាយករដ្ឋមន្ត្រីរបស់រដ្ឋាភិបាលចុងក្រោយរបស់ *លន់ នល់* ។ ទាំងអស់គ្នាចុះពីឡានយ៉ាងស្ងៀមស្ងាត់ រថយន្តក៏ត្រលប់ទៅវិញ ឯរបងក៏ត្រូវគេបិទជិតឈឹង ។

ក្នុងសំដីម៉ាត់ៗ ដែលគ្មានអោយអ្នកណាជំជែក រឺ ប្រកែកបានដូចពេលនៅអាកាសយានដ្ឋានដែរនោះ *ស៊ីវិន* ស្នើអោយយើងរៀបចំកន្លែងសំរាកនៅក្នុងបន្ទប់ដែលស្ថិតនៅពីក្រោយក្រសួង ។ បន្ទប់ទាំងនោះកាលដើមឡើយជាការិយាល័យ ។ នៅលើជញ្ជាំងមានគូសវាសអក្សរនិយាយពាក្យចំអេសចំអាសក្រវែមក្រវាំមពេញ ឯខ្សែភ្លើងធ្លាក់រតាត់រតាយល្បែនចេញគ្រប់កន្លែង ។ នៅកន្លែងខ្លះមានក្រដាសស្អាមផ្សេងៗ ទាំងគរៗ ។ នៅឯចុងម្ខាងនៃអគារយើង

ឃើញមានគ្រែដែកដែលគេគរចោលមួយគំនរ យើងក៏នាំគ្នាទៅសែងយកមករៀបចំនៅក្នុងគំនរសំរាមទាំងនេះ ។

មានមិត្តម្នាក់បានសាកសួរថា តើពួកយើងត្រូវរស់នៅកន្លែងបែបនេះប៉ុន្មានពេល ។

- នេះអាស្រ័យការភ្ញាក់រលឹកសតិអារម្មណ៍ និង នយោបាយរបស់មិត្តទាំងអស់គ្នាតែប៉ុន្នោះ ។ មួយខែ ពីរខែ រឺ ជួនកាលយូរជាងនេះទៅណា. . . នេះ គឺជាចំលើយ ។

ប្រធានក្រុមយើងបានព្រមានអោយដឹងថា បញ្ជាគឺហាមឡើងទៅជាន់លើនិង ទៅលើរានហាល ហាមដើរជិតរបងព័ទ្ធអគារ និង មិនត្រូវអោយមានលឺសំលេងខ្លះខ្ចាយទៅខាងក្រៅឡើយ ។ យើងត្រូវនៅក្នុងរង្វង់ចន្លោះអគារទាំង ២ ហើយត្រូវប្រយ័ត្នជានិច្ចមិន និងគ្រាប់បែកដៃដែលគេបង្កៃ ។

យើងបែងចែកកន្លែងសំរាក ។ អ្នកមានគ្រួសារស្នាក់នៅតាមការិយាល័យតូច១ នោះ ឯអ្នកលីវ១ នៅផ្តុំគ្នាក្នុងសាលធំ ។ ក្រោយពីរៀបចំកន្លែងត្រួស១នោះ ជាបឋមហើយ យើងក៏ចេញមកជុំគ្នានៅក្នុងទីធ្លា ។ នៅពេលនោះ យើងក៏បានឃើញឃុវនារី បីនាក់ ស្លៀកពាក់ខ្មៅដើរសំដៅមករកពួកយើង ។ ទាំងអស់ចោមរោមសំលឹងមើលនារី១ទាំងនេះ ។ នេះជា "យុទ្ធនារីបដិវត្ត" ហើយក៏ជាលើកទីមួយដែលពួកយើងបានជួបប្រទះវីរនារីទាំងនេះ ដែលគេតែងនិយាយហើយនិយាយទៀតនិងដែលចំរៀងតស៊ូតែងលើកឡើងពីសេចក្តី

ក្លាហានដ៏អស្ចារ្យនោះ ។ ពួកនាងគឺជា " នារសារបស់កងទ័ពព្រៃដែលរត់កាត់ព្យុះភ្លើងព្យុះគ្រាប់ដោយឥតភិតភ័យដើម្បីផ្តត់ផ្តង់យុទ្ធជន " " ជាយុទ្ធនារីដែលមានឆន្ទៈមុតស្រួចដូចដែកថែប " ។ យ៉ាងស្ម័គ្រចិត្ត និងក្នុងចរិតរាបសារ នារីទាំងនោះបានច្រាលចោលនូវតួនាទីសំរាប់តែចុះចាញ់របស់សង្គមចាស់ដើម្បីកាន់អាវុធ និង សំរេចបានស្នាដៃដ៏ត្រចះត្រចង់របស់ខ្លួន ។

យើងសំលឹងមើលនារីទាំង បី នាក់នេះរហូតធ្វើអោយពួកនាងអៀនខ្លួន។ ពួកនាងយកចានក្បាន និង បន្ទែបង្ការខ្លះមកអោយយើងដើម្បីធ្វើម្ហូបល្ងាច។ នាងមានកាយវិការនឹងធឹងហើយធ្ងន់ ។ដែលជាទំលាប់របស់នារីស្រុកស្រែ។ ដោយមានបទបញ្ជាយ៉ាងតឹងតែង ពួកនាងមិនបានឆ្លើយតបនឹងសំនួរទាំងឡាយរបស់ពួកយើងទេ ហើយពួកនាងក៏បានត្រលប់ទៅវិញបាត់យ៉ាងរហ័សទៅក្នុងកន្លែងមួយដែលក្រោយមកយើងហៅថាចង្រ្កាននោះ ។

នៅពេលល្ងាច *សុវិន* មកលេងយើងខ្ញុំ។ គាត់រាក់ទាក់នឹងខ្ញុំដោយញញឹមយ៉ាងស្រស់ធ្វើអោយខ្ញុំសង្ឃឹមថា គាត់នឹងប្រាប់ខ្ញុំពីការបកដល់របស់បង *សុវគ្ឃីន* នាពេលខាងមុខឆាប់ៗ នេះមិនខាន ។ តែខ្ញុំត្រូវខកចិត្តស្រលះក្នុងការរង់ចាំនេះ។ គាត់គ្រាន់តែសួគ្រឃ្លាដែលមានស្រាប់ៗប៉ុន្មានឃ្លា រួចក៏ចាប់ផ្តើមអួតដាក់ខ្ញុំនូវភាពលើសគេនៃបដិវត្តន៍ខ្មែរ លើបដិវត្តន៍មុនៗ កន្លងមក ពិសេសលើចំនុចបំបាត់លុយកាក់និងជំលៀសប្រជាជនចេញពីទីក្រុង។ ខ្ញុំស្តាប់យ៉ាងអត់ធ្មត់នូវសុន្ទរកថាដែលខ្ញុំបានចាំស្ទើរមិនចន្លោះពាក្យនេះ ។ ជាសុន្ទរកថាដូចគ្នា

នឹងសុន្ទរកថាបង *សុវគ្ឃីន* ដែរ ។

នៅ ប៉ារី *សុវិន* ជាយុទ្ធិកៈសកម្មមានចិត្តទូលាយម្នាក់ ។ ជាឪពុករបស់កូនប្រុស ពីរ នាក់ *សុវិន* រាក់ទាក់ទទួលភ្ញៀវមិនដាច់ ។ *វិជា* ប្រពន្ធ*សុវិន* ក៏ត្រូវបានអ្នកផងវាយតំលៃខ្ពស់ជាងកច្ឆន្ទ ។ ថ្វីត្បិតតែមានពូជពង្សជាអ្នកមានធំម្នាក់នៅ ខេត្តបាត់ដំបង តែនាងបានចូលធ្វើបដិវត្តន៍ដោយសេចក្តីស្នេហាជាតិ ។ ជាមនុស្សឆ្លាតវៃ និងរាប់យល់ចិត្តថ្នើមអ្នកផង *វិជា*បានក្លាយជាយុទ្ធិកាដ៏សកម្ម និងមានប្រសិទ្ធភាព ។ ម្តាយនាងដែលបានទៅលេងនាងនៅឯប៉ារីមុនព្រឹត្តិការណ៍ឆ្នាំ៧០ បានទៅតាមនាងនៅឯប៉េកាំង ។

ម្តាយរបស់*វិជា* រាងទាបទ្រនាប់មានសាច់ទ្រលុក តែមិនមែនធាត់ស្មៅចនោះទេ ។ គាត់កាត់សក់ខ្លី ហើយមានលក្ខណៈសក្តិសមជាអ្នកមានមុខមានមាត់ចំនាស់ខ្មែរម្នាក់ ។ នៅឯប៉េកាំងយាយបានចូលស្តាប់គ្រប់បទឧទ្ទេសនាមរបស់ *អៀង សារី* ដោយត្រងត្រាប់សំដីរបស់ *អៀង សារី* យ៉ាងអស់ពីពោះពីពុង ។ លុះដល់អាយុ ៧០ ឆ្នាំហើយទើបយាយមើលឃើញសម្បត្តិធនានានាដែលបង្កប់ក្នុងប្រទេស និង ក្នុងប្រជាជនយាយ ឧទាហរណ៍ ដូចជាយាយសែនរំភើបស្ទើរភ្លេចភ្លឺកនៅពេលយាយដឹងថា ភ្នំឱរ៉ាល់មានកំពស់ ១៨១៣ ម៉ែតជាដើម ។

យាយកាន់ពុទ្ធសាសនា ។ ប្រការនេះធ្វើអោយមនុស្សគ្រប់ៗ គ្នាគោរពយាយ ។ ប៉ុន្មានពេលចុងក្រោយនេះ សុខភាពយាយចុះដាបណាស់ ធ្វើ

អោយគ្រប់ៗគ្នាមានការព្រួយបារម្ភមែនទែន ដោយឃើញយាយនៅស្ពឹក ប៉ុន្តែ
នៅពេលទទួលដំណឹងដ៏យជំនះយាយបានដណ្តើមយកឈ្នះចិត្ត ហើយយាយ
ទើបមកដល់ភ្នំពេញនេះ ក្នុងដង្ហើមខ្យល់ជីវិតថ្មីមួយទៀតហើយ ។

យាយមានមោទនភាពចំពោះកូនប្រសារ និងកូនស្រីយាយណាស់ ។
យាយមានមោទនភាពចំពោះអង្គការ ដែលបានរំដោះប្រទេសអោយរួចពីការ
ជិះជាន់បរទេស ទោះបីជាក្នុងប្រការនេះយាយត្រូវបាត់បង់ទ្រព្យសម្បត្តិដែល
គ្រួសារយាយខំកសាងពួតផ្ទុំឡើងរាប់តំនក្តី ។ អ្វីដែលសំខាន់គឺអនាគតដែល
នៅក្នុងកណ្តាប់ដៃកូនៗ យាយ និងចៅៗ របស់យាយទៅវិញទេ ។

ក្នុងពេលស្រស់ស្រូបពេលល្ងាច *ស៊ីរិន* ឡើងដ្ឋែងជាផ្លូវការថា :

- អ៊ង្គការបានឈ្នុសឈ្នុល ដើម្បីរៀបចំពិធីជប់លៀងមួយ សក្តិសម
នឹងកម្មាភិបាលជាន់ខ្ពស់ ហើយដែលរៀបចំឡើងនេះ ដោយវីរយុទ្ធជនកម្ពុជា
ទាំងឡាយ ។ ក្នុងពេលរង់ចាំចុះទៅរួមសុខទុក្ខជាមួយប្រជាជន សមមិត្តទាំង
អស់គឺជាភ្ឿវរបស់យើងខ្ញុំ ។ ខ្ញុំសង្ឃឹមថាសមមិត្តទាំងអស់នឹងវាយតំលៃបាន
ថា តើអង្គការ * ផ្តល់កិត្តិយសយ៉ាងណាដល់សមមិត្តហើយ ។

នៅក្នុងសំដីបែបផ្លូវការ និងបែបបំពងយ៉ាងនេះ គ្មានអ្នកស្គាល់ថាជា
ស៊ីរិន ពេលមុននោះទេ ។ មើលៗ ទៅហាក់ដូចជា *ស៊ីរិន* កំពុងតែប្រដៅធមិ
អញ្ចឹង ។ *ស៊ីរិន* បន្តទៀត :

- បច្ចុប្បន្ននៅទីនេះគ្មានអង្ករទេ ។ អ្វីៗ ទាំងអស់ត្រូវបានបញ្ជូនទៅ

សហការណ៍ដើម្បីគាំទ្រមហាពលិកម្មក្នុងការកសាង និងទទួលអ្នកទីក្រុង ។
ប៉ុន្តែដើម្បីសមមិត្ត អង្គការបានរកបានអង្ករខ្លះ ... យុទ្ធជន យុទ្ធនារីបានសុខចិត្ត
ផ្តាច់ចេញពីមាត់ពីកដើម្បីសមមិត្តបានហូប ។ កន្លងមកនេះ បងប្អូនយុទ្ធជន
យើងហូបតែនំប៉ុងធ្វើពីម្សៅមីផ្ទូររបស់អាមេរិចតែប៉ុននោះ. . . ទៅមុខទៀត
សមមិត្តទាំងអស់ត្រូវហូបដូចគេដូចឯងដែរ ។ ចាប់ពីស្អែកទៅ សមមិត្តស្រស់
ស្រូបតែ ពីរ ពេលបានហើយលើកលែងតែកុមារទើបមានរបបពេលព្រឹក ។

យើងលេបលៀងចុងក្រោយរបស់យើង ដែលមានសំលស្តៃ ស្តៃឆា
ខ្លាញ់ បាយ និង នំប៉ុង ។ រួចមានមិត្តម្នាក់សួរពីរឿងក្មេងដែលត្រូវការបន្លែ
ស្រស់ ផ្លែឈើ ទឹកដោះគោ ស្ករ ... ជាដើម ពិសេសក្មេងដែលម្តាយមិនអាច -
បំបៅបាន ព្រោះថាអីលូវនេះពិតមែនតែម្តាយទាំងនោះមានដាក់ស្បៀងបង្ការ
មែន តែលុះតែពេលអស់នោះតើត្រូវធ្វើយ៉ាងណា ?

- ធ្វើយ៉ាងណា ? - *ស៊ីរិន* បន្ទរតាម- ធ្វើដូចប្រជាជនទៅណាំ ! កូន
ង៉ា និង កូនប្រជាជនម៉ែចរស់នៅកើត គេនោះ ! ហើយសតិអារម្មណ៍បដិវត្តគេ
ខ្ពង់ជាងមិត្តផង ។ សតិអារម្មណ៍មិត្តយ៉ាងនេះ ៗ ទើបឃើញថា អង្គការ
ឈ្លាសវៃណាស់ក្នុងការរក្សាពួកមិត្តនៅទីនេះសិននោះ ។ បើសិនជាប្រជាជន
លឹមិត្តនិយាយបែបនោះ គេដកមិត្តចេញភ្លាម ។



ព្រឹកស្អែកឡើង ខ្ញុំភ្ញាក់ពីព្រលឹម ។ មេឃស្រលះល្អ ។ ខ្ញុំស្ទុះក្រោកឡើងក្តុងអំនរីករាយ ហើយខ្ញុំភ្លេចអស់នូវទុក្ខកង្វល់ពីម្សិលម៉ិញ ។ ខ្ញុំគិតថារស់នៅទីនេះប្រហែលជាសុខដុមណាស់មើលទៅ ។ ថ្ងៃនេះពិតជាថ្ងៃល្អ ព្រោះថាបង *ស៊ីវគ្រីន* នឹងមករកខ្ញុំមិនខាន ។

ហើយទិវា ក៏បានរំលងផុតទៅដោយគ្មានដំណឹងអ្វីទាំងអស់ ។

ស្ថានភាព ជាភ្ញៀវរបស់យើងបានកត់សំគាល់នូវលក្ខណៈមិនច្បាស់លាស់ ដែលអង្គការរក្សាជាមួយយើង ក៏ដូចជាស្ថានភាពខុសគ្នាដែលអង្គការចង់បែងចែកច្បាស់រវាងរ្លកចាស់ និង រ្លកថ្មីយ៉ាងនោះដែរ ។ រ្លកចាស់ពីរ្លកដែលបានធ្វើសង្គ្រាម ឯពួកយើងគឺជារ្លកដែលមកពេលដែលសង្គ្រាមចប់ យ៉ាងនេះហើយទោះជាយើងមានស្មាដៃយ៉ាងណា ក៏មិនអាចទៅផ្ទឹមនឹងពួករ្លកចាស់នោះបានដែរ ។

តែគេក៏ប្រាប់ពួកយើងដែរថា ពួកយើងមានលក្ខណៈអំនោយផលយ៉ាងធំសំបើមជាងដែលពួកនៅឯស្រុកបារាំងទៅទៀត ។ ពួកយើងគ្រាន់បើជាង ដោយថាពួកយើងត្រូវបានបណ្តុះបណ្តាលឆ្លងកាត់ច្រើនវគ្គមកហើយ ។

គឺ ដោយបែបនេះហើយដែលអង្គការបែងចែកកន្លែងអោយយើងហើយនឹងដាក់យើងអោយប្រជែងគ្នាដើម្បីរត់ដណ្តើមអំនាច ។ ក្នុងពេលរង់ចាំថ្ងៃដ៏រីករាយដែលយើងមានសិទ្ធិទៅនៅជាមួយប្រជាជននោះ ពួកយើងត្រូវស្ថិតនៅក្នុងការពិនិត្យសិន ហើយម្នាក់ៗ ត្រូវតែខិតខំបញ្ចេញស្នាដៃទៅ ! ។

ជាក់ស្តែងម្នាក់ៗ ក៏ខំធ្វើការខ្លឹត ។ រ្លកខ្លះក៏ប្រឹងជួសជុលភ្លើងអគ្គិសនីអោយឆេះឡើងវិញ រ្លកខ្លះលាងកញ្ចក់ ដុសអិដ្ឋ ឯរ្លកខ្លះទៀតជំរះស្អៅតាមច្រកចូល និងធ្វើសួន ។

គេក៏បានបំផុសយើងអោយសើរើសំភារៈយើងម្តងទៀត និង យកចេញនូវរបស់អ្វីដែលមិនចាំបាច់ ។ តាមពិតមានច្រើននាក់ដែរ ដែលបានទុកសំភារៈផ្សេងៗ ដូចជាគ្រឿងប្រើប្រាស់សួនតូ វត្ថុអនុស្សាវរីយ៍ វិទ្យុ ម៉ាញ្ចូជាដើមនោះ ។

- បើមិត្តយើងនៅតែរក្សារបស់របរតិចណូឡូស៊ី បរទេស អង្គការមិនអាចបញ្ជូនមិត្តទៅនៅជាមួយប្រជាជនបានទេ ។ ប្រជាជនរស់នៅដោយគ្មានរបស់របរទាំងនេះទេ ។ ប្រជាជនរស់នៅមិនចាំបាច់មានអ្វីទាំងអស់ ។ សមមិត្តត្រូវតែរស់នៅដូចប្រជាជនអញ្ចឹង ។ ប្រជាជនល្អណាស់ បងប្អូនបូជាអ្វីៗ ជូនអង្គការទាំងអស់ សូម្បីតែកូនចៅដែលជាសាច់ឈាមខ្លួនផ្ទាល់ ក៏គេបូជាដែរ ។ សមមិត្តត្រូវតែយកតំរាប់តាមប្រជាជន ។ ដើម្បីចូលចុះក្នុងសង្គមថ្មី យើងត្រូវតែបន្ថយអីវ៉ែអីវ៉ាន់យើងមកនៅត្រឹមតែកូនបាឡូតូចមួយតែប៉ុននោះ ។

ជំរើសនេះ គឺល្អិតល្អន់ណាស់ ។ ក្នុងមួយបាឡូមានរបស់ចាំបាច់តែបន្តិចបន្តួចតែប៉ុននោះ ក្រៅពីនេះត្រូវប្រមូលដាក់នៅក្នុងបន្ទប់មួយសំរាប់ជូនអង្គការ ។ តំរូវទាមទារនេះដែលកាលពីពេលចេញដំណើរមានអ្នកច្រើនណាស់ដែលរអ៊ូរទាំនោះ ស្រាប់តែអីលូវនេះ ងាយដូចបកចេក ហើយគ្មានអ្នកណារអ៊ូ

រទាំមួយអ៊ីសឡើយ ។

នៅល្ងាចថ្ងៃទី បី កម្ពាភិបាលជាន់ខ្ពស់ម្នាក់បានមកដល់កន្លែងពួកយើង : គឺ *ខៀវ សំផន* ។ គាត់គ្រាន់តែមកមើលមួយភ្លែត ដោយមានទាំងការពារស្មាយកាំភ្លើង ពីរ នាក់ មកជាមួយផង ប៉ុន្តែទស្សនកិច្ចនេះ បានបង្ហាញនូវការយកចិត្តទុកដាក់របស់គេមកលើពួកយើង ។ នៅពេលនោះហើយដែលប្រធានក្រុម រឺ ដូចដែលយើងហៅយ៉ាងគោរពថា អ្នកទទួលខុសត្រូវលើអាយុជីវិតនោះ បានអោយយើងដឹងថា អង្គការនឹងចាត់តាំងវគ្គរៀនសូត្រមួយដើម្បីធ្វើការបំពាក់បំប៉ននយោបាយ ។ វគ្គនេះនឹងចាត់តាំងឡើងនៅក្នុងពេលវេលាជាលាក់ការណ៍មួយនៅឡើយ នៅក្នុងសាលសន្និសីទរបស់ទីស្តីការនាយករដ្ឋមន្ត្រីចាស់នោះឯង ។ អ្នកចូលវគ្គត្រូវសំរាកនៅនឹងកន្លែងរៀន ពោលគឺ តាមការិយាល័យនានាដើម្បីអោយសតិអារម្មណ៍ងាយប្រមូលផ្តុំ ។ ឯកុមារ។ នឹងត្រូវបានយុទ្ធនាវីដ៏ស្មោះត្រង់ទទួលបីបាច់ថែរក្សា ប្រកបដោយស្មារតីបដិវត្តខ្ពស់ ។

ពួកយើងត្រូវទទួលរៀបចំកន្លែងបើកវគ្គនេះ ។ យើងបានចុះប្រលូកភ្លាមឥតបង្អង់ ។

គួរអោយចំលែកម្យ៉ាង ដោយថាភារកិច្ចដែលគេស្ងះស្វែងជាងគេ គឺការដុសលាងបង្គន់ទៅវិញ ។ ជនជាតិខ្មែរខ្ពើមអាច់ទាល់តែមែនទែន* ជូបកន្លែងណាគេតែងងាកភ្នែក និងដើរចៀសចេញហើយ ។ ប៉ុន្តែក្នុងជំនោរខ្យល់

បដិវត្តដែលកំពុងបក់នេះការជំនះលើល្មើមរបស់ខ្លួនគឺ ជាសក្តីភាព នៃប៉ំលែងសតិអារម្មណ៍ហើយ ។

នៅក្នុងបង្គន់តាំងពីជញ្ជាំងទៅ មានសុទ្ធតែអាច់ ។ នេះជាឱកាសល្អមួយដើម្បីបង្ហាញគោលជំហរ ។ អ្នកខ្លះរកបានទុយោបាញ់ទឹក អ្នកខ្លះរកបានក្រណាត់កន្ទប ឯអ្នកខ្លះទៀតអង់អាចរហូតដល់យកដៃដុសបង្គន់ រឺ យកក្រចកកោសអាច់ថែមទៀតផង ។

នៅឯជាន់លើ ការិយាល័យនានានៅអគារឆ្វេងដៃត្រូវគេបែងចែកសំរាប់បុរស ការិយាល័យនៅអគារស្តាំសំរាប់ស្ត្រីដែលមានកូនខ្ចី ឯការិយាល័យនៅចំកណ្តាលរបស់អតីតនាយករដ្ឋមន្ត្រី *ឡុង បូរេត* ត្រូវក្លាយជាកន្លែងសំរាប់ស្ត្រីឯទៀតទៅវិញ ។

បន្ទប់នេះធំទូលាយប្រណិត ។ ខ្ញុំភ្ញាក់ផឹងខ្លួនឯងដែលចូលក្នុងបន្ទប់នេះដោយថ្ពប។ ជើង ។ នៅពីមុខតុធំមួយប្រកបដោយក្បាច់ភ្លីផ្សេង។ នោះមានកៅអីដូលរាត់រាយច្រវេងច្រវាង ។ រូបថតរបស់ លន់ នល់ មួយត្រូវគ្រាប់ចំទ្រូងបែកកញ្ចក់ខ្ចេច ក៏មាននៅទីនេះដែរ ។ ឯកសារគ្រប់បែបយ៉ាងនៅរាយប៉ាយពាសពេញអិដ្ឋ។ បន្ទប់នេះនៅយ៉ាងរបៀបនេះ តាំងពីល្ងាចនៃថ្ងៃកាន់កាប់ទីក្រុងភ្នំពេញម្ល៉េះ ។ គេបាននិយាយថា *ឡុង បូរេត* បានរង់ចាំកងទ័ពរំដោះដោយអង្គុយនៅពីក្រោយតុរបស់ខ្លួន ។ នៅពេលយុទ្ធជនដំបូង។ បានមកដល់គាត់បានងើបឈរដោយលូកដៃទៅផង ប៉ុន្តែក៏មានការប្រវាយប្រតុបគ្នាឡើង

ហើយលោកនាយករដ្ឋមន្ត្រី ក៏បានសាកសត់តេចតាមទ្វារក្រោយ .....

ខ្ញុំដើរតំរង់ទៅរកទ្វារតូច ហើយបើកវាដោយភ័យ។ ព្រោះអតីតកាលថ្មីៗ នេះហាក់ដូចជារស់រវើកពេកតែម្តង ។ ខ្ញុំឃើញមានជណ្តើរគូថខ្សែងមួយ ហើយខ្ញុំក៏ចុះជណ្តើរនេះទាំងបេះដូងឱបខ្លាក់ ដោយក្រែងប្រទះឃើញរឿងរ៉ាវនេះ ...

-នៅពេលដែលយើងរៀបចំស្រេចបាច់ហើយ ក៏លេចមាននារីមួយក្រុមដែលជាអតីតអ្នកបំរើរបាមព្រះអង្គម្ចាស់ *សីហនុ* នោះមករួមរស់នៅជាមួយពួកយើងដែរ ។ អ្នកមានអាយុច្រើនជាងគេបានកោរក្បាលតាមប្រពៃណី ។ យើងបានផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ។

ដល់អញ្ចើងទៅបន្ទប់ដេករបស់យើងរួមមានគ្រែ ៥០ ដែលដាក់ប្រជ្រៀតគ្នាណែនក្តន់ធ្វើអោយខ្ញុំនឹកឃើញយ៉ាងចត់ នូវអនុស្សាវីយ៍កាលពីខ្ញុំនៅអន្តេវាសិកដ្ឋានដែរ ។

នៅពេលហៀបនឹងលង់លក់នៅវេលាយប់នេះ ខ្ញុំហាក់ដូចជាច្បាស់នៅក្នុងចិត្តថា ពេលវេលាគង់តែមកដល់ឆាប់ៗ ក្រោយពីសិក្ខាសាលានេះ ជាពេលដែលខ្ញុំនឹងជួបបង *ស៊ីរគឿន* ហើយយើងនឹងចាកចេញទៅរបូត ។

នៅវេលាព្រឹកស្អែកឡើង ទាំងអស់គ្នាបានចូលទៅអង្គុយយ៉ាងរមទម្យដូចនៅក្នុងវិហារនៅឯសាលប្រជុំ ហើយពេលដែល *ខៀវ សំផន* ចូលមកដល់ យើងបានទះដៃយ៉ាងយូរ និងយ៉ាងខ្លះខ្លារ ។ ក្នុងឱកាសជាមហោឡារិកនេះ យើងទាំងអស់គ្នាបានស្នើកពាក់ខោអាវផាឱបខ្ចៅ ដែលធ្វើអោយបរិយាកាសគោរពប្រណិបត្តិ ស្មើរដូចគោរពសាសនានេះកាន់តែអោយខ្ញុំមានអារម្មណ៍ហាក់ដូចជារួមក្នុងពិធីបុណ្យសំងាត់អីមួយយ៉ាងនោះដែរ ។

ពេលដែល *ខៀវ សំផន* ឡើងអង្គុយលើវេទិកាកិត្តិយសហើយគាត់ក៏សំលឹងមួយត្រួសមើលអង្គប្រជុំ រួចងាកទៅរក *ស៊ីរិន* ដែលអង្គុយនៅក្បែរនោះ។ បន្ទាប់ពីខ្សិបប៉ុន្មានម៉ាត់ដាក់ត្រចៀក- *ស៊ីរិន* មក *ខៀវ សំផន* ក៏ក្រោកឈរ ហើយដើរចេញពីក្នុងសាលទៅ ។ *ស៊ីរិន* ក៏ងើបឡើងនិយាយស្នើអោយពួកយើងចេញពីសាលប្រជុំផងដែរ ។ ទាំងអស់គ្នាក៏ធ្វើតាម ។

នៅពេលដែលខ្ញុំចេញផុតពីក្លោងទ្វារ *ស៊ីរិន* បានមកជួបខ្ញុំហើយបាននាំខ្ញុំទៅដាច់ពីគេ ។ ភ័យបារម្ភបន្តិច។ ដោយខ្លាចបង *ស៊ីរគឿន* មានរឿងអីធំដុំនោះ ខ្ញុំខំប្រឹងស្តាប់យ៉ាងយកចិត្តទុកដាក់នូវអ្វីដែល *ស៊ីរិន* ត្រូវការនិយាយប្រាប់ខ្ញុំ ។ គាត់និយាយពង្វាងចុះពង្វាងឡើង :

- សភាពការណ៍នៅក្នុងប្រទេសយើងក្រោយជ័យជំនះ ១៧ មេសា មកគឺស្មុគស្មាញ ។ មិនដែលមានពេលណាដែលចក្រពត្តិនិយមអាមេរិចត្រូវគេវាយអោយបរាជ័យទាំងស្រុងដូចពេលនេះទេ ។ តែប្រទេសចិនខ្លួនឯង ក៏រំដោះ

តែវ៉ាន់ មិនបានផង ។ ក្ងរេក៏នៅតែចែកជា ពីរ ។ ឯវៀតណាមវិញ ក៏ជ័យជំនះ មួយផ្នែកអាស្រ័យដោយការតស៊ូរបស់វីរប្រជាជនយើងដែរ ។ បើររត់ពួកយើង ពួកវានៅតែកំពុងវៃគ្នានៅឡើយទេ ។

អញ្ចឹងទៅ ថ្ងៃ ១៧ មេសា គឺជាជ័យជំនះរបស់វីរប្រជាជនមួយដែល មានតែបាតដៃទទេលើមហាអំនាចសេដ្ឋកិច្ច នយោបាយ និង យោធា ។ ជ័យ ជំនះនេះជារបស់ប្រជាជនខ្មែរ ហើយជារបស់ប្រជាជនខ្មែរតែមួយគត់ ...

- ចាស ! ចាស ! - ខ្ញុំខំឯកភាពយ៉ាងនឹងន ក្នុងពេលដែលក្នុងចិត្តខ្ញុំ កំពុងរហន់ស្នើរដាច់ខ្យល់ ដោយខ្ញុំឃើញគេទាំងអស់គ្នាចូលក្នុងសាលប្រជុំវិញ ហើយ ៗ ខ្ញុំខ្លាចចូលយឺតជាងគេ ។

ស៊ីរិន បន្តទៀត :

- ប្រទេសកម្ពុជា ប្រជាជនកម្ពុជា (គេឈប់ប្រើពាក្យ Cambodge (1) និង Cambodgien ទៀតហើយ ព្រោះគេថាពាក្យនេះជាកេរ របស់អាណានិគម និយម) គឺពិតជាអង់អាច ។ មិត្តដឹងទេ ថាប្រជាជនលំបាក វេទនាខ្លាំងដោយសារអាណានិគមនិយម និង ពួកអាណានិគមនិយមបារាំង នោះ ? ជ័យជំនះថ្ងៃ ១៧ មេសា គឺប្រជាជនដណ្តើមបានដោយខ្លួនឯងផ្ទាល់ មិត្តយល់ទេ ?

---

(១) តាមពិតទៅពាក្យ កាំបូត (cambodge) គឺថាពាក្យ កម្ពុជា សរសេរបែបបារាំងតែ ប៉ុននោះឯង

រប្យៀបបែបខ្មែរ (រឺហោចណាស់រប្យៀបពួកខ្មែរក្រហម) ដែលមិន និយាយចំសាច់រឿងនេះ ធ្វើអោយខ្ញុំវង្វេងវង្វាន់អស់ ។

- អោយខ្ញុំយល់ពីអី ?

- ក្នុងប៉ុន្មានថ្ងៃនេះ មិត្តមានភារកិច្ចមើលថែទាំកូនមិត្តសិនចុះ ហើយ បើមិត្តព្រម នោះមើលកូនអ្នកឯទៀតផង ហើយចាំក្រោយអង្គការនឹងគិតគូរពី មិត្ត ។

ភាន់ភាំងនឹងអាជ្ញាអយុត្តិធមិនេះ ហើយដោយមិនអាចធ្វើអ្វីកើត ក៏ ដូចជាមិនអាចទប់ទល់សញ្ចេតនាបាន ខ្ញុំបែរក្បាលហើយដើរចេញពីកន្លែងនោះ យ៉ាងរហ័សទៅប្រមូលយកអីវែអីវ៉ាន់ រួចខ្ញុំដើរសំដៅទៅកន្លែងក្មេងៗ សំរាក ។ ក្មេងទាំងអស់កំពុងតែយំទ្រហឹងអឹងអាប់ ។ ក្លិនទឹកនោមធុំឈួលដល់ច្រមុះខ្ញុំ ។ ក្មេងខ្លះកំពុងទាររកអីហូប ខ្លះកំពុងតែគ្រុន ។ ខ្លួនប្រាណក្មេងៗ មានសុទ្ធតែ ស្នាមមូសខាំកន្ទួលកន្ទ្រើស ។ ចំនែកវីរយុទ្ធនារីរបស់អង្គការ ពួកគេកំពុងដេក លក់ដូចគល់អុស ។ ខ្ញុំដូរកន្ទបក្មេងដែលនោម បោកកន្ទេល និងជូតអិដ្ឋ ឯក្មេងៗ នៅតែបន្តយំទ្រហឹងអឹងអាប់ដដែល ។

ប្រផ្ទួលអាក្រក់ជាច្រើនបានទន្ទ្រានចូលក្នុងខួរក្បាលខ្ញុំ ។ តិចខ្ញុំធ្លាក់ ចុះក្នុងអន្ទាក់ទៅ ? រឺតិចក៏អ្វីៗដែល គេនិយាយប្រាប់ខ្ញុំគ្រាន់តែជាការកុហក មួយ ? ខ្ញុំប្រឹងទប់ទល់នឹងគំនិតនេះ ប៉ុន្តែសំលេងមួយនៅក្នុងខ្លួនខ្ញុំនៅតែចចេស បន្លឺឡើង : ឯងជាអ្នកជាប់ឃុំឃាំង ! ជាប់ឃុំឃាំង ! ពួកគេចង់សងសឹក សង

សីកលើរូបឯង ។ ខ្ញុំដឹងថាការប្រឹងទប់ទល់របស់ខ្ញុំកំពុងតែត្រូវរង្គោះរង្គើហើយ ។ ខ្ញុំធ្លាប់ស្គាល់ពេលឯកោ និងការសង្ស័យដែរ ហើយខ្ញុំតែងទប់ទល់បានជានិច្ច ប៉ុន្តែម្តងនេះខ្ញុំបាក់ហើយ ។

ទឹកភ្នែកខ្ញុំចាប់ផ្តើមហូរធ្លាក់ខ្លាក។ ដូចជានៅពេលណាដែលគេប្រឹងទប់ឃ្លាតណាស់មកហើយយ៉ាងនោះដែរ ។ ខ្ញុំបោកក្រណាត់កន្ទបបណ្តើរ យំសស្រាក់បណ្តើរ ដោយមិនអាចទប់ទឹកភ្នែកមិនអោយហូរចុះបាន ។

យុទ្ធនារីបដិវត្តទាំង ពីរ ដែលបានភ្ញាក់ឡើងជួនពេលនេះនោះ ក៏សំលឹងមើលមកខ្ញុំទាំងភ្ញាក់ផ្អើល និងទាំងលំបាកចិត្ត ហើយត្រៀមជាស្រេចនឹងទទួលស្គាល់កំហុសឆ្គងរបស់ខ្លួន ។ ខ្ញុំក៏មានការរំខាននៅក្នុងចិត្តណាស់ដែរ-ប៉ុន្តែខ្ញុំមិនអាចទប់ទឹកភ្នែកបានទេ ។ទឹកភ្នែកខ្ញុំចេះតែជោរជន់ស្រក់ចេញជោក ។

បោកគក់រួចរាល់ហើយខ្ញុំយកវាទៅហាល ។ ព្រឹកនេះព្រះអាទិត្យចាំងចែងពន្លឺព្រចេះ ធ្វើរោយខ្ញុំកក់ក្តៅនៅក្នុងដួងចិត្តបន្តិច ។

ថ្ងៃបន្តបន្ទាប់មក ខ្ញុំមើលថែទាំកុមារ។ ដោយនាំក្មេង។ទាំងនោះដើរលេងចុះឡើង។ ក្នុងទីធ្លាដែលគេកំនត់អោយយើងនោះ ។ ខ្ញុំនាំក្មេងច្រៀងនិយាយរឿងដែលខ្ញុំប្រឌិតរោយស្តាប់ ហើយដល់ពេលបាយខ្ញុំចាត់ចែងរោយក្មេង។ ហូបសំលស្មៃជាអលជ្ជីនោះ ។

នៅពេលដែលឪពុកម្តាយកុមារទាំងនោះ ចេញសំរាកចន្លោះម៉ោងពួកគេធ្វើជាមិនដឹង មិនលឺ មិនឃើញខ្ញុំសោះឡើយ ។

វគ្គអប់រំនយោបាយដែលម្ភាក់។ ត្រូវតែនិយាយលំអិតនូវជីវិតខ្លួនសកម្មភាពខ្លួន ការភាន់ច្រលំរបស់ខ្លួនដោយទិព្វៀន និងស្ងួយទិព្វៀន(១) យ៉ាងម៉ឺងម៉ាត់នេះ មានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើចិត្តគំនិតមនុស្ស ដោយវាមានកំលាំងកាច់ពត់ចិត្ត គំនិតទៅតាមគំនូសសតិអារម្មណ៍មួយដែលគេរៀបចំហើយស្រេចនោះបាន ។

ជាថ្មីម្តងទៀតខ្ញុំត្រូវគេចង្អុលថាជាអ្នកជ្រែករំខាន ជាខ្មាំង ។ ខ្ញុំត្រូវវិលត្រលប់ទៅរកស្ថានភាពខ្ញុំកាលពីប៉ុន្មានឆ្នាំមុនពេល *អៀង សារី* ទៅប៉ៃកាំងនោះដដែល ។ ខ្ញុំគឺជា ស៊ីស៊ីប (២) នៅឯជើងភ្នំ ប៉ុន្តែលើកនេះខ្ញុំមិនមានចំនង់និងក៏គ្មានកំលាំងគ្រប់គ្រាន់ដើម្បីឡើងភ្នំជាថ្មីម្តងទៀតឡើយ ។ ការងារនេះហួសពីកំលាំងរបស់ខ្ញុំ ហើយក៏វាមិនស្របទៅនឹងការគិតពីតួនាទីដែល ខ្ញុំអាចបំពេញបាននៅឯកម្ពុជានេះសោះឡើយ ។

វគ្គរៀនសូត្រចប់ យើងក៏វិលមករកកន្លែងចាស់របស់យើងវិញដើម្បី

---

(១) ស្មេរបានប្រើពាក្យ Critique et autocritique (រិះគន់និងស្ងួយរិះគន់) តែដោយយោលលើរបៀបនៅក្នុងសម័យនោះ ពាក្យរិះគន់ដែលមានន័យថា ការសំលឹងពិនិត្យពិចារណាដោយប្រើវិចារណញ្ញាណនោះមិនត្រូវទេ ហេតុនេះខ្ញុំបានប្រើពាក្យ " ទិព្វៀន " ដែលមានន័យថា "ការនិន្ទា" ពេបជ្រាយផ្សេង។ ពិតខ្លះមិនពិតខ្លះ" ខុសទាំងស្រុងក៏មាន " មកជំនួសវិញ ។

(២) តួអង្គក្នុងរឿងព្រេងក្រិចដែលត្រូវបណ្តាសារអោយប្រមៀលថ្មឡើងភ្នំ ហើយជានិច្ចកាលថ្មនេះត្រូវធ្លាក់ទៅក្រោមវិញនៅពេលហៀបដល់កំពូល ហើយស៊ីស៊ីប ត្រូវតែចុះទៅប្រមៀលឡើងទៅវិញទៀតជាអលជ្ជីបែបនេះ (ក.អ.ប.)

រង់ចាំការសំរេចរបស់អង្គការ ។ ម្នាក់ៗ បំពេញការងាររៀង ៗ ខ្លួន ដោយលាក់យ៉ាងជិតនូវគំនិតត្រិះរិះរបស់ខ្លួន ។ ខ្លួនខ្ញុំដែលយល់ច្បាស់ពីការចងខ្លួនខ្ញុំចេញនោះ ខ្ញុំក៏នៅឆ្ងាយពីមិត្តភក្តិខ្ញុំទាំងនោះហើយរង់ចាំការមកដល់របស់បង *ស៊ីគ្វីន* ។

ល្ងាចមួយ ក្រោយពេលទទួលទានពេលល្ងាចរួចមក នៅក្នុងអ្វីដែលបានក្លាយជាបន្ទប់ខ្ញុំទៅហើយនោះ និង នៅក្នុងពេលដែលខ្ញុំកំពុងបង្រៀនកូនអោយចេះគូរ សួរដើងនៅឯជណ្តើរបានរសាត់មកដល់ខ្ញុំ ធ្វើអោយបេះដូងខ្ញុំលោតកញ្ឆ្រោល ។ មុខខ្ញុំឡើងក្តៅភាយ ។សួរដើងនេះ ខ្ញុំធ្លាប់ស្គាល់មិនច្រលំសោះឡើយ តាំងពីពេលខ្ញុំទើបរៀបការ ហើយរស់នៅឯប៉ារីសាកលវិទ្យាល័យម្ល៉េះ គឺ បង *ស៊ីគ្វីន* ។ ខ្ញុំលោតទៅពោងកគាត់ទាំងអំនរ ។ បង*ស៊ីគ្វីន* អោបក្អេងថើប ។ យើងទាំងអស់គ្នាសែនសប្បាយរីករាយម្ល៉េះទេ ។

ខ្ញុំសួរទៅគាត់ ពីគាត់ធ្វើការនៅកន្លែងណា ? គាត់ធ្វើអ្វី ? ប៉ុន្តែបង *ស៊ីគ្វីន* ឥតបានឆ្លើយតបឡើយ ដោយគាត់អនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការលាក់ការណ៍ដែលគាត់រំលឹកថា គឺនេះ ហើយដែលជាកត្តាកំនត់ជីវិតជំនះ ១៧ មេសានោះ ។ ខ្ញុំក៏បោះបង់ចោលគំនិតចង់ដឹងរបស់ខ្ញុំទៅ ប៉ុន្តែខ្ញុំក៏បានសារភាពទៅគាត់ពីកំហុកចិត្តរបស់ខ្ញុំផងដែរ ។ គាត់ឆ្លើយតបវិញ :

- ត្រូវទុកចិត្តអង្គការ * ចុះ ព្រោះអង្គការដឹងច្បាស់ពីអ្នកឯង ជាងអ្នកឯង ។ ហើយអង្គការនឹងមានកន្លែងគ្រាន់បើជាងនេះសំរាប់អ្នកឯងណា !

- កន្លែងអីទៅ ?

បង *ស៊ីគ្វីន* មិនឆ្លើយ ព្រោះគាត់ក៏មិនដឹងដែរ ប៉ុន្តែគាត់ចេះតែឆ្លើយតាមរបៀបដែលគេបង្រៀនគាត់អោយឆ្លើយតែប៉ុននោះ ។ ទោះជាយ៉ាងនេះក្តី ខ្ញុំក៏ខំស្រមៃតោងគំនិតដែលថាអង្គការនឹងយកខ្ញុំចេញពីនេះ ហើយនឹងប្រើប្រាស់នូវចំនេះដឹងរបស់ខ្ញុំមិនខាន ។

ពិតមែន មួយរយៈពេលបន្តិចមក អង្គការដែលពេញចិត្តចំពោះដំណើរប្រព្រឹត្តទៅរបស់វគ្គនោះ បានអោយពួកយើងដឹងថា គ្រប់គ្នានឹងចេញដំណើរក្នុងពេលឆាប់ៗ នេះទៅឯ "មូលដ្ឋាន" ពោលគឺប្រជាកសិករហើយ ។

- ល្ងាចនោះ រថយន្តស៊ីបមួយគ្រឿងបានចូលមកដល់ទីធ្លា- ហើយបង *ស៊ីគ្វីន* ក៏ចេញមកពីក្នុងឡាន :

- អង្គការ * អោយបងមកយកអូនហើយ ។ រៀបចំអីវែអីវ៉ាន់ទៅហើយកុំប្រាប់អ្នកណាទាំងអស់ណា !

បី នាទីក្រោយមកជាមួយនឹងកូន អីវែអីវ៉ាន់ទាំងអស់ ខ្ញុំបានចាកចេញពីទីកន្លែងនេះ ដោយឥតបានលាមិត្តភក្តិខ្ញុំណាម្នាក់ឡើយ ។

រថយន្តបើកចេញតាមរបងទ្វារ មកដល់មហាវិថីមួយរួចរត់បានប្រហែល ៥០០ ម៉ែត ក៏បត់ចូលទៅឈប់ក្នុងទីធ្លាមួយវិញ ។ យប់ងងឹតឈឹប ។ យើងចុះពីលើឡានហើយខ្ញុំដើរតាមបង *ស៊ីគ្វីន* ដែលដើរក្នុងងងឹតយ៉ាងធូរល្អែង ។ យើងឆ្លងកាត់សាលចំមួយ ចេញទៅទីធ្លាក្នុង ដើរតាមបណ្តោយជញ្ជាំង

រួចនៅទីបញ្ចប់ខ្ញុំបានឃើញបន្ទប់តូចមួយមានពន្លឺឆេះនៅខាងក្នុង ។ មនុស្ស ម្នាក់បានដើរមកជួបនឹងពួកយើងគឺ *គ្រានលាន* ។

- ពួកយើងទើបដឹងដំណឹងពីការមកដល់របស់មិត្ត ។ ខាងយុទ្ធនាវីគេ កំពុងរៀបចំជប់លៀងមិត្តណា ។ ទៅ ! យកអីវ៉ាន់ទៅទុកទៅ គេរៀបចំហើយ តែអីលូវណឹង (គ្រានលាននិយាយ) ។

បដិសណ្ឋារកិច្ចដ៏រាក់ទាក់នេះ ធ្វើអោយបេះដូងខ្ញុំបាត់ចុកចាប់អស់ ។ ខ្ញុំបានភ្លេច បី អាទិត្យដ៏សែនវេទនាដែលខ្ញុំទើបបានឆ្លងកាត់ក្នុងពេលរង់ចាំពេ សំរេចពីជោគវាសនាខ្ញុំនោះអស់រលីង ។

ជាអតីតនិស្សិត ប៉ូស្ទ *គ្រានលាន* បានបកនៅខាង *ស៊ីហនុ* នៅឯ ប៉េកាំង ក្រោយពីមានរដ្ឋប្រហារមក ។ *លាន* បានត្រូវតែងតាំងជានាយខុទ្ទកា ល័យរបស់ *ប៉ិន នុត* រួចនៅចំពោះបំនងចង់ចូលរួមការតស៊ូក្នុងប្រទេសរបស់ *លាន* ។ បានឆ្លងកាត់រយៈពេលហ៊ឹកហឺនមួយរយៈ ហើយនៅខែ មករា ១៩៧៣ ដែលជាសម័យដែលអាមេរិចកំពុងសំរុកទំលាក់គ្រាប់បែកយ៉ាងខ្លាំងក្លា លើ កម្ពុជានោះ *លាន* ត្រូវបានបញ្ជូនមកតំបន់រំដោះជាមួយនឹងក្រុមបញ្ជាជនមួយ ក្រុម ដែលមានគ្នាប្រហែលដប់ប្រាំនាក់ ។ ការតស៊ូបានធ្វើអោយ *លាន* ក្លាយជា អ្នកកាន់អំនាចមួយ ។

ដើម្បីទៅដល់កន្លែងស្នាក់នៅ គេត្រូវកាត់ក្នុងភាពងងឹតឈឹង ជា អលជ្ជីនេះ នូវច្រកតូចចង្អៀតមួយពោរពេញដោយរថយន្តកាំម៉ូង ដែលគេបោះ

បង់ចោល ។ យើងដើរវាវពពើម ដើម្បីជៀសវាងកុំអោយមានរបួសព្រោះការ ទង្គិចនឹងឡាននោះ ។

បន្ទប់សំរាកស្ថិតនៅជាន់ទី មួយ ។ ក្នុងអ្វីដែលពីដើមជាចង្ក្រានបាយ នោះបង *ស៊ីគ្លឿន* បានរៀបចំគ្រែមួយសំរាប់គាត់ហើយស្រេច ។ កូនស្រីខ្ញុំ និង ខ្ញុំបានបន្ទប់មួយ ។ បន្ទប់មួយទំនេរគ្មានអ្នកណានៅទេ ។ បន្ទប់ទីកនៅឯចុង របៀង ។

ក្នុងបន្ទប់យើងមានតែគ្រែដែកមួយគត់ និងទូតូចមួយ ។ ជាប់នឹងទ្វារ មានព្យួរប្រតិទិន អាមេរិចមួយ ដែលបើកចំហចោលនៅចំទំព័រខែ មេសា ហើយដែលជាអនុស្សាអីយ៏ចុងក្រោយរបស់អ្នកម្ចាស់ទីកន្លែងនេះមុន ។ ថ្ងៃ នីមួយៗ សុទ្ធតែមានគំនូសឆូត ។ នៅត្រង់ថ្ងៃទី ១០ មានសរសេរថា Rain (ភ្លៀង) ។ នេះប្រហែលជាភ្លៀងដើមដៃហើយមើលទៅ ។ ថ្ងៃទី ១១ មាន សរសេរថា Nothing (គ្មានអ្វីទាំងអស់) ។ ថ្ងៃទី ១២ ឃើញមានឆូតដែរ រួច គ្មានអ្វីទាំងអស់ ។ តាមបែបនេះ គឺជនជាតិអាមេរិចម្នាក់បានរស់នៅក្នុងបន្ទប់ នេះ នៅក្នុងថ្ងៃចុងក្រោយមុននឹងចាកចេញពីទីក្រុងភ្នំពេញយ៉ាងសស្ងើតសស្ងប់ នោះ ។ ខ្ញុំសាកល្បងស្មានពីមនុស្សនោះថាតើមាឌធំរឺទេ ? សក់ទង់ដែងរឺ ទេ ? តើជននោះភ័យខ្លាចទេ ? ។

ជាថ្មីម្តងទៀតខ្ញុំមានអារម្មណ៏ដូចជាធ្លាក់ទៅក្នុងអតីតកាលមួយថ្មី។ ។ សង្គ្រាមនៅបង្ហាញមុខរបស់វានៅឡើយ ហើយខ្ញុំហាក់ស្ទាបដឹងពីភាពរញួយ

នៃប្រវត្តិសាស្ត្រផងដែរ ។

បង *ស៊ីគឿន* និយាយមកកាន់ខ្ញុំ :

- អង្គការ * ផ្តល់កិត្តិយសអូនសំបើមណាស់ ដែលអនុញ្ញាតអោយអូនឯងរស់នៅកន្លែងនេះ ។

នៅលើតុជប់លៀងមានសំលមួយឆ្នាំង សំលឆាមួយចាន មានបាយនំប៉័ង ស្ករ និងចេកច្បើន ។ ទាំងអស់នេះបង្ហាញឡើងនូវសប្បុរសធម៌មួយដ៏កក់ក្តៅ ។

គ្រានលាន និយាយពីនេះពីនោះក្នុងពេលកំពុងហូបបាយ ប៉ុន្តែនៅពេលស្តាប់ *គ្រានលាន* ខ្ញុំមានអារម្មណ៍ចំលែកដូចកាលពេល ខ្ញុំជួប *សុវិន* អញ្ចឹងដែរ ។ កាយវិការរបស់ *គ្រានលាន* ជាកាយវិការហាត់ពត់ ហើយសំដីរបស់គេជាសំដីបោះពុម្ពដែលផ្តិតយកត្រង់ៗ ពីសំដីផ្ទួវការរបស់ *អៀង សារី* និង របស់អ្នកដឹកនាំឡៃតៗ ដែរ ។

គ្រានលាន រំលឹកឡើងយ៉ាងមហាផ្ទួវការពីពលិកម្ម និង វីរភាពរបស់កងទ័ព របស់ប្រជាជន ។ *លាន* បានសំដែងនូវការស្រលាញ់ និង ភក្តីភាពរបស់ខ្លួនចំពោះអង្គការ * ដែលជាឪពុកម្តាយរបស់ខ្លួន ហើយប្តេជ្ញាយករស់កំលាំងកាយចិត្តបំរើប្រជាជន ។

លាន បាននិយាយថា នៅពេលដែលធ្លាក់ខ្លួនឈឺធ្ងន់ មានកសិករក្រម្នាក់ បានយកមាន់ ដែលជាសម្បត្តិទ្រព្យតែមួយរបស់គាត់យកមកអោយ

ហើយពលិកម្មនេះបានធ្វើអោយ *លាន* បានឆាប់ជាសះស្បើយ ។

គោរពតាមបទបញ្ជាលាក់ការណ៍ ខ្ញុំទប់ចិត្តមិនសាកសួរពីមិត្តរួមរបស់យើងឡើយ ។ ប៉ុន្តែខ្ញុំចង់ដឹងម្ល៉េះទេពីជោគវាសនារបស់ *កាម៉ាញ់ .វ៉ារិទ្ធ . ជាវេត* ដែលបានមកតស៊ូក្នុងប្រទេស ហើយដែលខ្ញុំសង្ឃឹមថា នឹងបានជួបនៅឯភ្នំពេញនោះ ។

ពេលបាយចប់ *គ្រានលាន* សួរខ្ញុំ :

- និយាយអញ្ចឹង មិត្តដាក់ឈ្មោះអីទៅ ?

នៅក្នុងជួរ យុទ្ធជនម្នាក់ៗ ត្រូវស្នើអោយដូរឈ្មោះ ប៉ុន្តែខ្ញុំមិនដែលនឹកថារឿងនេះមានទាក់ទិនដល់ខ្ញុំទេ ដល់អញ្ចឹងហើយពេលដែល *លាន* សួរខ្ញុំ ។ ក៏ស្រលាំងកាំងតែម្តង ។

- អូនដាក់ឈ្មោះ *ផល* ទៅ (បង *ស៊ីគឿន* ស្នើឡើង) ។

ផល មានន័យថាផ្លែ ជាការដុះដាល ។ ឈ្មោះនេះពេញចិត្តខ្ញុំ ។ ខ្ញុំនឹកគិតក្នុងខ្លួនសូមអោយការងាររបស់ខ្ញុំបានទទួលជោគជ័យតាមឈ្មោះនេះផងចុះ ។

ម្យ៉ាងទៀតដោយដឹងច្បាស់ថា ជនជាតិកម្ពុជា ពូកែក្នុងការដាក់ឈ្មោះណាស់ ដោយហេតុនេះឈ្មោះ *ផល* (Phâl) ដែលរួមមានក្បាលតួអក្សរឈ្មោះខ្ញុំផងនោះ(Picq) ពិតជាមិនមែនរើសដោយចៃដន្យនោះឡើយ ។

- ល្អណាស់ (ខ្ញុំឆ្លើយ) ។

យើងទាំងអស់គ្នាងើបចេញពីតុ ។ ពិធីបង្គក់ខ្ញុំអោយទៅជាខ្មែរបានចប់សព្វគ្រប់ហើយ ។

នៅពេលដែលចូលដល់អ្វីដែលជា " កន្លែងសំរាក " របស់ខ្ញុំនោះ ខ្ញុំឃើញមានយុទ្ធនារីជាច្រើននាក់កំពុងរៀបចំដាក់កន្ទេល ខ្ទើយនិងបង្គោលមុង ។

- សួស្តី (ខ្ញុំឧទ្ធានឡើង) ។

ពួកនាង។ ងើបក្បាលមើលមក តែមិនឆ្លើយតបទេ ហើយក៏បន្តការងាររបស់ខ្លួនទៅទៀត យ៉ាងយកចិត្តទុកដាក់ ។ ខ្ញុំផ្តេសផ្តាសមែន ! ដូចជាប្រការដែលអ្នកផងបានបាត់ទំលាប់ចាប់ដៃគ្នា រឺ សាកសួរផ្សេង។ អញ្ចឹងដែរ ការនិយាយជំរាបសួរគ្នា ក៏ចិនមែនល្អដែរ ។ ថ្ងៃមុខថ្ងៃក្រោយខ្ញុំត្រូវតែទំលាប់ខ្លួន ។

នៅពេលដែលកូនស្រីទាំងពីរ របស់ខ្ញុំមកដល់ យុទ្ធនារីទាំងនោះ ក៏ប្រលែងលេង អោបថើប ចាក់ក្រលេក រឹទះកំប៉ែះគូថក្រពុង ។ របស់ពួកវា ។ របៀបស្រលាញ់ខ្មែរនេះខុសផ្សេងពីរបៀបចិន ហេតុនេះទើបកូនស្រីខ្ញុំទាំងពីរភ្ញាក់ផ្អើលណាស់ដែរ ប៉ុន្តែពួកវាមិននិយាយស្តីអ្វីទេ ។ ជាថ្មីម្តងទៀត ខ្ញុំសាកល្បងទាក់ទងជាមួយយុទ្ធនារីទាំងនេះដោយចាប់ផ្តើមសាកសួរឈ្មោះពួកនាង ។ ដំបូងពួកនាងឆ្លើយតបនឹងខ្ញុំទាំងញញើតញញើម រួចបន្តិចម្តងក៏ចាប់ផ្តើមហ៊ាននិយាយស្តី ។ ពួកនាងរំភើបរីករាយពេលឃើញកូនស្រីខ្ញុំទាំងពីរ ដោយពួកនាងនឹកឃើញប្អូនស្រី ។ របស់ខ្លួនដែលពួកនាងបានបែកចេញមកនៅពេលចូលបំរើ

រង្គការ ។

ពេលគេចេញទៅវិញអស់ហើយ ខ្ញុំក៏ចាប់ផ្តើមរៀបចំទុកដាក់អីវ៉ែអីវ៉ាន់ និងស្វែងយល់ដឹងពីផ្ទះថ្មីរបស់ខ្ញុំនេះ ។ បង្គោលមុងមានសណ្ឋានដូចជាអង់តែនយ៉ាងចំលែកអស្ចារ្យតែម្តង រីមួយក៏ពួកយើងនៅក្នុងផ្នែកមួយនៃស្ថានីយ៍វិទ្យុទេដឹង ?

នៅពេលយប់ជ្រៅ ស្រាប់តែបង *ស៊ីគឿន* មកដាស់ខ្ញុំ :

- មកអោយឆាប់ឡើង មានការងារបន្ទាន់ !

គាត់ពន្យល់ខ្ញុំយ៉ាងខ្លីថា *អ៊ូង សារី* ត្រូវចេញដំណើរវេលាព្រឹកស្អែកឆ្ពោះទៅបាងកក ដោយហេតុនេះគេត្រូវការបកប្រែសេចក្តីប្រកាសពត៌មានមួយដែល *អ៊ូង សារី* ត្រូវយកទៅជាមួយនេះ ។ បង *ស៊ីគឿន* បន្ថែមថាការងារនេះ គឺជាការបង្ហាញនូវទំនុកចិត្តរបស់អង្គការ * ហើយ ។ ខ្ញុំចាប់ផ្តើមបកប្រែយ៉ាងរហ័ស ដោយវិភាគឃ្លានីមួយៗថ្នឹងថ្នែងពាក្យមួយម៉ាត់ៗ តាមគោលការណ៍នយោបាយ និងតាមក្បួនដែលខ្ញុំធ្លាប់រៀននៅឯប្រទេសចិន ។

បង*ស៊ីគឿន* ដែលនៅអង្គុយជិតខ្ញុំ ដើម្បី " ជួយ " ខ្ញុំនោះលាន់មាត់ឡើង :

- អូនឯងគ្រាន់បើណាស់អីលូវនេះ !

- ខ្ញុំនៅខ្វះខាតច្រើនណាស់ - ខ្ញុំឆ្លើយតបនឹងគាត់ប៉ុន្តែនៅក្នុងចិត្តខ្ញុំសែនសប្បាយរីករាយពន់ពេក ។